**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការរៀបចំធ្វើ
# និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **កុសល បញ្ញារិទ្ធិ** | **លោក អ៊ឹង រដ្ឋា** |
| **ថោង ធនវឌ្ឍន៍** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ទី ២១ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

នៅក្នុងវិថីឆ្ពោះទៅរកភាពជោគជ័យមួយ មិនមែនជាការណ៍ដែលងាយស្រួលនោះទេ ហើយក៏មិនអាចធ្វើទៅរួចតែឯកឯងបាននោះឡើយ ប្រាកដណាស់ទាមទារឲ្យមានអ្នកជុំវិញលើកទឹកចិត្ត និងការឧបត្ថម្ភគាំទ្រពីសំណាក់ មជ្ឈដ្ឋានជុំវិញខ្លួន ទើបអាចទទួលបានសមិទ្ធផលប្រកបទៅដោយផ្លែផ្ការបាន។

យ៉ាងណាមិញក្នុងនាមយើងខ្ញុំជានិស្សិតឈ្មោះ កុសល បញ្ញារិទ្ធិ និងនិស្សិតឈ្មោះ ថោង ធនវឌ្ឍន៍ ដែលថ្មីៗនេះ ទើបតែទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ក៏ដោយសារទទួលបានការជួយជ្រោមជ្រែងពីតួអង្គសំខាន់ៗ ដែលនៅក្នុងនោះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសំដែងភាពកតញ្ញូកតវេទីគោរពជូនចំពោះ៖

-លោកឪពុក និងអ្នកម្ដាយ ជាព្រះរស់ទាំងទ្វេរ ដែលមានព្រហ្មវិហារធម៌ និងគុណូបការៈ ដែលមានអាចកាត់ថ្លៃបានចំពោះកូនៗ ផងដែរមានលោកយាយ លោកតា អ៊ុំ ពូមីង បងប្អូនជាដើម ដែលតែងតែជួយមើលការខុសត្រូវ និងទូន្មាន ប្រៀនប្រដៅ ដល់រូបយើងខ្ញុំ។

-លោក **អ៊ឹង រដ្ឋា** ជាសាស្ត្រាចារ្យណែនាំដ៏មានគុណបំណាច់មួយរូប ក្នុងការជួយជ្រំជ្រែងឲ្យសារណារបស់យើងខ្ញុំបញ្ចប់ទៅដោយលក្ខណៈគ្រប់ជ្រុងជ្រោយ និងល្អប្រសើរ តាមរយៈការប្រឹងខ្នះខ្នែងពន្យល់ ណែនាំផ្ដល់ជាមតិយោបល់ល្អៗ និងការរៀបចំ ការកែតម្រូវនូវខ្លឹមសារអត្ថបទជាដើម។

**-រាជរដ្ឋាភិបាល ក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមសកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ មន្ត្រីរដ្ឋបាល** និងបុគ្គលិកបម្រើការងារនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដោតលើគុណភាពនៃការអប់រំជាកត្តាទីមួយ ដោយបានខិតខំខ្នះខ្នែងគ្រប់គ្រង ដឹកនាំ បង្ហាត់បង្រៀន ប្រកបទៅដោយការយកចិត្តទុកដាក់ដើម្បីធ្វើការបណ្ដុះបណ្ដាលនិស្សិតឲ្យក្លាយទៅជាធនធានមនុស្ស ប្រកបដោយមានគុណភាព គុណធម៌ និងភាតរភាព ជាពិសេសឲ្យទៅជាយុវជនគម្រូ និងជាសសរទ្រូងយ៉ាងរឹងមាំសម្រាប់ទ្រទ្រង់ប្រទេសជាតិ ប្រកបដោយ សន្តិសុខ យុត្តិធម៌ និងការអភិវឌ្ឍន៍។

-ឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មាធិការទី១០ នៃរដ្ឋសភា អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពត ជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋានខេត្តកំពត និងជាប្រធានមូលនិធិ

សម្រាប់និស្សិតខេត្តកំពត ដែលបានផ្តល់អាហារូបករណ៍ដោយឧបត្ថម្ភជាប្រាក់សោហុយវិភាជន៍ដល់រូបខ្ញុំបាទ ថោង ធនវឌ្ឍន៍ បន្តការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ រយៈពេល៤ឆ្នាំ បានដោយជោគជ័យ។

ដោយអំណាចនៃគុណានុភាព ដែលពួកលោកបានប្រតិបត្តិ គឺយើងខ្ញុំគ្មានអ្វីជាការតបស្នង ជាជុំកំភួន ជូនចំពោះរូបលោកនេះទេ មានតែសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី មេត្តាជួយបីបាច់ថែរក្សា ពួកលោក អោយទទួលបាននូវ សុខភាពល្អបរិបូរណ៍ ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ សេចក្តីសុខចម្រើន និងជោគជ័យគ្រប់ភារកិច្ចជានិរន្ត៍។

សូមពួកលោកជួបតែសេចក្តីសុខ សុភមង្គល និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ១១ រោច ខែទុតិយាសាធ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

# អារម្ភកថា

សៀវភៅសារណាស្តីពី "**នីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ**" ដែលយើងខ្ញុំទាំងពីរបានរៀបចំចងក្រងឡើងជាសៀវភៅនេះ គឺដើម្បីក្នុងគោលបំណងចែករំលែកនូវចំណេះដឹង និងពុទ្ធិ ចំពោះបងប្អូនសិស្ស និស្សិត លោកពូ អ្នកមីង បងប្រុស បងស្រី ជាពិសេសអ្នកដែលចង់ដឹងអំពីនីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ សម្រាប់ជាទុកទុនបម្រុង ក៏ដូចជាមូលដ្ឋានគ្រឹះក្នុងការសិក្សាឱ្យបានទូលំទូលាយនូវមុខវិជ្ជានីតិអន្តរជាតិសាធារណៈ ។

ចំពោះការស្រាវជ្រាវនេះ គឺជាការចង្អុលបង្ហាញ និងណែនាំដោយសាស្ត្រាចារ្យ **អ៊ុំ រដ្ឋា** ជាសាស្ត្រាចារ្យច្បាប់មួយរូបដែលទទួលបានសញ្ញាប័ត្រខ្ពស់ និងមានចំណេះដឹងទូលំទូលាយ ផ្នែកនីតិអន្តរជាតិសាធារណៈ ដែលជានីតិមួយប្រភេទ ដែលមានសារៈសំខាន់សម្រាប់បងប្អូនមិត្តនិស្សិត ដែលចង់សិក្សាអំពីមុខវិជ្ជានេះ សម្រាប់បម្រើការឱ្យវិស័យខាងក្រសួងការបរទេស ទោះបីវាជាផ្នែកមួយនៃមុខវិជ្ជាដែលទាក់ទងនឹងកិច្ចការងាររដ្ឋ ឬក្រុមហ៊ុនក៏ដោយ វាត្រូវបានគេយកទៅសម្រាប់ក្នុងការទំនាក់ទំនងផ្នែកការទូត ដែលស្ថិតនៅក្រោមក្រសួងមានសមត្ថកិច្ចក្នុងការបើកកិច្ចសហប្រតិបត្តិការ ក្នុងនាមរដ្ឋជាមួយនឹងរដ្ឋ អង្គការអន្តរជាតិនឹងអង្គការអន្តរជាតិ ។

ប្រធានបទ នីតិវិធីនៃការរៀបចំ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ នេះបានរៀបរាប់អំពីនីតិវិធីនីមួយៗរហូតដល់សន្ធិសញ្ញាចូលជាធរមានហើយត្រូវបានយកមកអនុវត្តដោយរដ្ឋជាសមាជិក ឬរដ្ឋហត្ថលេខី ចំពោះសន្ធិសញ្ញា ដែលរដ្ឋសភារបស់ខ្លួនបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា។ ការរៀបចំនីតិវិធីពិតជាមានការស្មុគស្មាញ ប៉ុន្តែប្រសិនបើយើងយកចិត្តទុកដាក់ក្នុងការអាន និងតាមដានអំពីនីតិវិធីនីមួយៗ នោះហាក់បីដូចជាដំណើររឿងមួយ ដែលមានតាំងពីដើមដល់ចប់ដែលទាក់ទាញមិត្តអ្នកអានឱ្យចង់ត្រង់ត្រាប់ស្តាប់ជាចំណេះដឹងក្នុងខ្លួន រួមតែការចែករំលែកទៅដល់ញាតិមិត្តបងប្អូន។ ការសិក្សាអំពីដំណើរការ ដោយតាមនីតិវិធីនីមួយៗមានការពន្យល់ពីអត្ថន័យនៃពាក្យបច្ចេកទេសជាច្រើន ដែលគេប្រើសម្រាប់ផ្លូវទូត កិច្ចការអន្តរជាតិរវាងបណ្តាប្រទេសនៅលើសកលលោក។

ទន្ទឹងនឹងនេះខ្ញុំបាទនៅតែមានភាពជឿជាក់ថា ទោះបីជាមានការខិតខំរៀបរៀង និងពិនិត្យយ៉ាងលម្អិតប្រកបទៅដោយភាពយកចិត្តទុកដាក់ទៅលើសារណាមួយក្បាលនេះ យ៉ាងណាក៏ដោយក៏នៅតែមាននូវចន្លោះខ្វះខាតទាំងផ្នែកអក្ខរូប អក្ខរស និងអក្ខរាវិរុទ្ធដោយអចេតនាជាក់ជាពុំខាន។ យើងខ្ញុំសូមសូមខន្តីអភ័យទោស

ទុកជាមុននូវរាល់កំហុសឆ្គង ដោយអចេតនា ហើយខ្ញុំបាទនឹងទទួលនូវរាល់ការរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងនិសិត្សទាំងអស់គ្រប់មជ្ឈដ្ឋានទាំងអស់។

ជាចុងបញ្ចប់ខ្ញុំបាទសូមជូនពរជ័យដល់អស់លោក លោកស្រី មិត្តអ្នកអាន លោកសាស្ត្រាចារ្យ និងនិស្សិតទាំងអស់ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................................................ ១

## ជំពូកទី ១
## សញ្ញាណទូទៅសន្ធិសញ្ញាអន្តរជាតិ

**ផ្នែកទី១៖ និយមន័យនៃសន្ធិសញ្ញាអន្តរជាតិ** ........................................ ៤

កថាខណ្ឌទី១ ប្រភពជាតិ ........................................ ៤

កថាខណ្ឌទី២ ប្រភពអន្តរជាតិ ........................................ ៥

កថាខណ្ឌទី៣ សណ្ឋាននៃសន្ធិសញ្ញា ........................................ ៥

កថាខណ្ឌទី៤ ការប្រើប្រាស់ពាក្យពេចន៍ ........................................ ៦

**ផ្នែកទី២៖ ធាតុផ្សំនៃសន្ធិសញ្ញាអន្តរជាតិ ក្នុងន័យទូទៅ** ........................................ ៧

កថាខណ្ឌទី១៖ ឯកសារជាលាយលក្ខណ៍អក្សរ ........................................ ៧

កថាខណ្ឌទី២៖ ធ្វើឡើងដោយអ្នកដែលមានបុគ្គភាពគតិយុត្ត ........................................ ៧

កថាខណ្ឌទី៣៖ មានគោលដៅបង្កើតអានុភាពគតិយុត្ត ........................................ ៨

កថាខណ្ឌទី៤៖ កិច្ចព្រមព្រៀងត្រូវចែងដោយនីតិអន្តរជាតិ ........................................ ៨

**ផ្នែកទី៤៖ វិធាននៃនីតិអន្តរជាតិ** ........................................ ៨

**ផ្នែកទី៥៖ សន្ធិសញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងតួអង្គនានានៃនីតិអន្តរជាតិ** ........................................ ១០

## ជំពូកទី ២
## ការរៀបចំធ្វើសន្ធិសញ្ញាអន្តរជាតិ

**ផ្នែកទី១ ល័ក្ខខ័ណ្ឌទម្រង់** ........................................ ១១

កថាខណ្ឌទី១ សន្ធិសញ្ញាក្នុងន័យទូទៅ ........................................ ១១

១.ការចរចា ........................................ ១១

២. ការចុះហត្ថលេខាលើសន្ធិសញ្ញា ........................................ ១៣

៣. ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ........ ១៣
កថាខណ្ឌទី២៖ អនុសញ្ញាពហុភាគីទូទៅ ........ ១៤
១. ល័ក្ខខ័ណ្ឌនៃការតាក់តែង ........ ១៥
២. ល័ក្ខខ័ណ្ឌនៃការចូលរួម ........ ១៦
៣. ការចូលជាធរមាននៃអនុសញ្ញាពហុភាគីទូទៅ ........ ១៦
៤. ខដាក់ល័ក្ខខ័ណ្ឌ ........ ១៧
កថាខណ្ឌទី៣៖ កិច្ចព្រមព្រៀងទម្រង់សាមញ្ញ ........ ១៨
កថាខណ្ឌទី៤៖ អនុសញ្ញារវាងអង្គការអន្តរជាតិ ........ ១៩
**ផ្នែកទី២ ល័ក្ខខ័ណ្ឌគ្រឹះនៃសន្ធិសញ្ញាអន្តរជាតិ** ........ ២០
កថាខណ្ឌទី១៖ វិការៈនៃការយល់ព្រមរបស់ភាគី ........ ២០
១. ការចាប់បង្ខំ ........ ២០
២. ការភាន់ច្រឡំ ........ ២១
៣.ការបំភាន់ ឬការលួចបន្លំ ........ ២២
កថាខណ្ឌទី២៖ ភាពខុសច្បាប់នៃកម្មវត្ថុរបស់សន្ធិសញ្ញា ........ ២៣
កថាខណ្ឌទី៣៖ អានុភាពនៃមោឃភាពនៃសន្ធិសញ្ញា ........ ២៣

## ជំពូកទី ៣

## ការប្រតិបត្តិ សន្ធិសញ្ញាអន្តរជាតិ

**ផ្នែកទី១៖ នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញាអន្តរជាតិ** ........ ២៥
**ផ្នែកទី២៖អនុភាពសន្ធិសញ្ញាចំពោះតតិយរដ្ឋ** ........ ២៨
**ផ្នែកទី៣៖ ការបកស្រាយសន្ធិសញ្ញាអន្តរជាតិពេលជួបខ្លឹមសារនៃសន្ធិសញ្ញានេះ** ........ ២៨
កថាខណ្ឌទី១៖ គោលបំណងនៃអ្នកបង្កើត ........ ២៩
កថាខណ្ឌទី២៖ ការបកស្រាយទូលាយ ........ ៣០
១.១ អត្ថន័យ ឬនិយមន័យ ........ ៣១
១.២ ស្ថានភាពសង្គម ........ ៣១
១.៣ ការប្រៀបធៀប និងការអនុវត្ត ........ ៣២

ផ្នែកទី៤៖ ការធ្វើវិសោធនកម្មលើសន្ធិសញ្ញា ........ ៣៣
ផ្នែកទី៥៖ ការរួចផុតពីការទទួលខុសត្រូវពេលមិនអនុវត្តសន្ធិសញ្ញាអន្តរជាតិ ........ ៣៤

## ជំពូកទី ៤
## ការបិទបញ្ចប់សន្ធិសញ្ញាអន្តរជាតិ

ផ្នែកទី១៖ ការផុតរលត់នៃសន្ធិសញ្ញា ........ ៣៦
កថាខណ្ឌទី១៖ ការបិទបញ្ចប់ដោយឆន្ទៈរបស់ភាគី ........ ៣៦
កថាខណ្ឌទី២៖ ការបិទបញ្ចប់ដោយមូលហេតុផ្សេងៗ ........ ៣៧
ផ្នែកទី២៖ការបញ្ចប់សុពលភាពគតិយុត្តរបស់សន្ធិសញ្ញាអន្តរជាតិ ........ ៣៩
**សេចក្តីសន្និដ្ឋាន** ........ ៤០
**អនុសាសន៍** ........ ៤១
**ឯកសារយោង** ........ ៤២
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំ និងបុព្វហេតុនៃការស្រាវជ្រាវ

នៅក្នុងក្របខ័ណ្ឌនីតិសាស្ត្រ រដ្ឋបាលសារធារណៈ វិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ក្រោមឆ័ត្រនៃនីតិអន្តរជាតិសារធារណៈ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតអោយមានប្រព័ន្ធគ្រប់គ្រងពិភពលោកមួយច្បាស់លាស់។

ផងដែរនៅក្នុងន័យ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរកិច្ច សង្គមកិច្ច វប្បធម៌ អំណាចទន់ ...ល...។ វាក៏ត្រូវបានចាត់ទុកថាជាឧបករណ៍ និងមធ្យោបាយ ដែលមានតម្លៃគតិយុត្ត ដែលបង្កើតអោយមានផលប្រយោជន៍សន្តិសហវិជ្ជមាន រវាង តួរអង្គ នៃនីតិអន្តររដ្ឋ។

‟ច្បាប់ ត្រូវបានរៀបចំឡើង ដើម្បីធ្វើការគ្រប់គ្រងនូវស្ថានការណ៍”។ ក្នុងរដ្ឋអធិបតេយ្យមានច្បាប់ផ្ទៃរាបជាតិ ចំណែកឯនៅក្នុងផ្ទៃរាបអន្តរជាតិ ស្ថានការណ៍នីមួយៗដែលកើតឡើង គឺត្រូវបានគ្រប់គ្រង់ និងចាត់ចែងដោយនីតិអន្តរជាតិ។ តួរយ៉ាងក្នុងសម័យកាលសហសម័យយើងនេះ បើទោះបីនីតិអន្តរជាតិ បានចាប់បដិសន្ធិយូរគួរសមយ៉ាងណាក៏ដោយ តែសំណុំលិខិតតូបករណ៍អន្តរជាតិដែលមានតម្លៃ អាចរៀបចំចាត់ចែងដំណើរការ ក៏ដូចជាការប្រព្រឹត្តទៅ និងនីតិវិធីនានា ហាក់បីដូចជាមានបរិមាណនៅមានកំរិតឡើយ នេះបើយើងធ្វើការប្រៀបធៀបជាមួយនឹងនីតិផ្ទៃរាបជាតិ។ នេះមិនទាន់និយាយដល់សេចក្តីពន្យល់ ផង។

ក្នុងសម័យកាលអន្តរកត្តា ដែលអាចរាប់ចាប់តាំងពី បម្រែបម្រួលនៃប៉ូលរបស់ពិភពលោក ជំងឺរាតត្បាតកូវី- ១៩ ជម្លោះនៃភូមិសាស្ត្រនយោបាយរបស់មហាអំណាច ព្រះរាជាណាចក្រកម្ពុជាដែលកំពុងស្ថិតនៅចន្លោះ បាននិងកំពុងទទួលបានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សទាំងក្នុងថ្នាក់ជាតិ ទាំងក្នុងថ្នាក់តំបន់ និងទាំងក្នុងឆាកអន្តរជាតិ។ ទល្ហឹករណ៍ដូចបានរៀបរាប់ខាងលើនេះ អាចអោយយើងមើលឃើញថា ការយល់ដឹង និងការជាក់ច្បាស់អំពីនីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ ពីសំណាក់អ្នកច្បាប់ការទូតរបស់កម្ពុជា នឹងនាំមកនូវលាភការ និងផលប្រយោជន៍ដ៏ឧត្តុងឧត្តម ជូនជាតិ មាតុភូមិ ដែលនេះក៏ជាបុព្វហេតុដែលនាំអោយមានការសិក្សាស្រាវជ្រាវលើប្រធានបទនេះឡើង ពីសំណាក់ក្រុមយើងខ្ញុំ។

## ២.ចំណោទបញ្ហា

នៅក្នុងពិភពលោកទាំងមូលមានសន្ធិសញ្ញាចំនួន១៦,០០០ ដែលបានចុះហត្ថលេខានៅរវាងរដ្ឋនឹង រដ្ឋនៅកំឡុងឆ្នាំ១៩៨១-១៩២៤ ដែលនៅក្នុងនោះមានសន្ធិសញ្ញាចំនួន១០.០០០ ប៉ុណ្ណោះដែលបានចូលជាធរមាន ហើយមានតែ០៣ប៉ុណ្ណោះដែលបានប្បញ្ញត្តិអំពីនីតិសន្ធិសញ្ញាអន្តរជាតិ។ ដោយមួយក្នុងចំណោមបីនោះ មិនទាន់បានចូលជាធរមាននៅឡើយ (អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៨៦ ស្តីពីនីតិវិធីនៃសន្ធិសញ្ញា រវាងអង្គការអន្តរជាតិ ឬរវាងរដ្ឋ នឹងអង្គការអន្តរជាតិ)។ ដោយមើលឃើញអំពីកង្វះខាតនៃលិខិតតូបករណ៍ ស្តីពីនីតិសន្ធិ សញ្ញាអន្តរជាតិ ព្រមទាំងឯកសារជាខេមរភាសា ប្រធានបទមួយនេះ នឹងធ្វើការសម្រាយ និងផ្តល់ជាឧទាហរណ៍ទាក់ទងទៅនឹង នីតិវិធីនៃការចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ ដោយជាពិសេសនឹងធ្វើការជីកកកាយទៅលើចំណោទគតិយុត្ត មួយចំនួនទាក់ទិនទៅនឹងការប្រើប្រាស់ពាក្យពេចន៍ ដោយផ្អែកទៅលើសណ្ឋាន (ដោយគូសបន្ទាត់អោយដាច់រវាង ប្រភេទកិច្ចព្រមព្រៀងអន្តរជាតិនីមួយៗ) និងចំណោទបញ្ហាគតិយុត្តមួយទៀត ដែលបាននិងកំពុងលេចឡើងជាច្រើនករណី គឺពេលដែលសន្ធិសញ្ញាចូលជាធរមានរួច តែរដ្ឋហត្ថលេខីមានការយល់ឃើញខុសគ្នា ឬមិនស្របគ្នាអំពីអត្ថន័យ ឬកម្មវត្ថុដែលនោះនឹងធ្លាក់ទៅលើចំណុចនៃការបកស្រាយសន្ធិសញ្ញា។

## ៣.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសិក្សាលើប្រធានបទស្តីពី"**នីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ**" គប្បីធ្វើការជ្រាបអំពីប្លង់គ្រឹះនៃការស្រាវជ្រាវ ដូចខាងក្រោមៈ

**ជំពូកទី១ សញ្ញាណទូទៅនៃសន្ធិសញ្ញាអន្តរជាតិ**

**ជំពូកទី២ នីតិវិធីនៃការរៀបចំធ្វើសន្ធិសញ្ញាអន្តរជាតិ**

**ជំពូកទី៣ ការប្រតិបត្តិសន្ធិសញ្ញាអន្តរជាតិ**

**ជំពូកទី៤ ការបិទបញ្ចប់សន្ធិសញ្ញាអន្តរជាតិ**

# វេយ្យស័ព្ទគតិយុត្ត

ក.ពាក្យថា "**ការផ្តល់សច្ចាប័ន**" "**ស្វីការ**" "**ការអនុម័ត**" និង "**ការសុំចូលជាសមាជិក**" មានន័យទៅតាមសកម្មភាពដែលរដ្ឋបានបង្ហាញនូវការយល់ព្រមទទួលស្គាល់សន្ធិសញ្ញាមួយនៅក្នុងផ្ទៃរាបអន្តរជាតិ។

ខ.ពាក្យថា "**សិទ្ធិប្រទាន**" មានន័យថាជាឯកសារដែលកើតចេញពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋ ក្នុងការតែងតាំងបុគ្គលណាម្នាក់ ឬមួយក្រុម ដែលតំណាងអោយរដ្ឋក្នុងការចរចា អនុម័ត ឬបញ្ជាក់ភាពត្រឹមត្រូវ របស់អត្ថបទនៃសន្ធិសញ្ញា សំរាប់បង្ហាញនូវការយល់ព្រមទទួលស្គាល់នូវសន្ធិសញ្ញា ឬបំពេញនូវកិច្ចផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសន្ធិសញ្ញា។

គ.ពាក្យថា "**ការធ្វើខដាក់ល័ក្ខខ័ណ្ឌ**" មានន័យថាជាសេចក្តីថ្លែងការជាឯកតោភាគី ដែលធ្វើឡើយដោយរដ្ឋនៅពេលចុះហត្ថលេខា ពេលផ្តល់សច្ចាប័ន ពេលធ្វើស្វីការ ពេលអនុម័ត ឬពេលសុំចូលជាសមាជិកនៃសន្ធិសញ្ញាណាមួយ ដោយសេចក្តីថ្លែងការណ៍នោះធ្វើការអះអាងបដិសេធ ឬធ្វើការកែប្រែនូវអានុភាពគតិយុត្តរបស់បទបញ្ញត្តិណាមួយនៃសន្ធិសញ្ញានៅក្នុងការអនុវត្តរបស់រដ្ឋនោះ។

ឃ.ពាក្យថា "**ភាគីចរចា**" មានន័យថា រដ្ឋដែលបានចូលរួមនៅក្នុងការតាក់តែង និងយល់ព្រមទៅនឹងអត្ថបទនៃសន្ធិសញ្ញា។

ង.ពាក្យថា "**ភាគីសន្យា**" ជារដ្ឋដែលបានទទួលស្គាល់សន្ធិសញ្ញា បើទោះជាសន្ធិសញ្ញានោះបានចូលជាធរមានឬក៏មិនទាន់បានចូលជាធរមានក៏ដោយ។

ច.ពាក្យថា "**ភាគី**" មានន័យថា រដ្ឋដែលបានទទួលស្គាល់សន្ធិសញ្ញា ហើយសន្ធិសញ្ញានោះបានចូលជាធរមានហើយ។

ឆ.ពាក្យថា "**តតិយរដ្ឋ**" មានន័យថា រដ្ឋដែលមិនមែនជាភាគីនៃសន្ធិសញ្ញា។

ជ.ពាក្យថា "**អង្គការអន្តរជាតិ**" មានន័យថាជា អង្គការអន្តររដ្ឋាភិបាល។[1]

[1] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩), បកប្រែក្រៅផ្លូវការ អ៊ីវ ប៉ូលី, មាត្រា ២។

# ជំពូកទី១
# សញ្ញាណទូទៅសន្ធិសញ្ញាអន្តរជាតិ

## ផ្នែកទី១៖ និយមន័យនៃសន្ធិសញ្ញាអន្តរជាតិ

ចំពោះការផ្តល់និយមន័យលើពាក្យសន្ធិសញ្ញា យើងគួរសង្កេតទៅលើពីរប្រភពចម្បងដែរមានដូចជា ប្រភពជាតិ និងប្រភពអន្តរជាតិ។ លើសពីនេះទៅទៀតសន្ធិសញ្ញាមានច្រើនប្រភេទ ហើយមានកម្មវត្ថុដាច់ដោយឡែកពីគ្នា ដូច្នេះសន្ធិសញ្ញាក៏ស្តែងឡើងតាមច្រើនរូបភាព និងពាក្យពេចន៍ផ្សេងៗគ្នាផងដែរ តែយ៉ាងណាមិញ ក៏ស្ថិតនៅក្រោមមូលដ្ឋានតែមួយ។

### កថាខណ្ឌទី១ ប្រភពជាតិ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ បានផ្តល់និយមន័យ "សន្ធិសញ្ញា" ដែលមានភ្ជាប់ក្នុង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ថា "ជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋនិងរដ្ឋ រវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ហើយស្ថិតក្រោមការគ្រប់គ្រងនៃនីតិអន្តរជាតិសារធារណៈ ទោះបីជាកិច្ចព្រមព្រៀងនោះមានឈ្មោះអ្វីក៏ដោយ (ធម្មនុញ្ញ សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា ពិធីសារ កិច្ចព្រមព្រៀង អនុសារណៈនៃយោគយល់ ...ល...) ដើម្បីបង្កើតអានុភាពគតិយុត្ត[2]។

ពាក្យ "សន្ធិសញ្ញា" មានន័យថាជាសេចក្តីព្រមព្រៀងអន្តរជាតិរវាងរដ្ឋនិងរដ្ឋ ឬរវាងរដ្ឋនឹងអង្គការអន្តរជាតិ ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវគ្រប់គ្រងដោយនីតិអន្តរជាតិ បើទោះបីតំណាងអោយលិខិតតូបករណ៍មួយតែមួយ ឬលិខិតតូបករណ៍ពីរ ឬច្រើនដែលមានទំនាក់ទំនងគ្នា និងបើទោះបីជាមានឈ្មោះយ៉ាងណាក៏ដោយ[3]។ តាមន័យនេះ កិច្ចព្រមព្រៀងដែលធ្វើឡើយដោយផ្ទាល់មាត់ ពុំមានធ្វើការចារឹកជាលាយលក្ខណ៍អក្សរ មិនអាចចាប់ទុកជាសន្ធិសញ្ញាបាននោះទេ។ ចំណែកឯឃ្លាដែលបានលើកឡើងថា "គ្រប់គ្រងដោយច្បាប់អន្តរជាតិ" សំដៅថាកម្មវត្ថុ ត្រូវតែស្របទៅនឹងច្បាប់អន្តជាតិ ជាពិសេសអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩។ អនុលោមតាមអត្ថន័យខាងលើ រដ្ឋមិនអាចចុះកិច្ចព្រមព្រៀងធ្វើសន្ធិសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បាននោះឡើយ។

[2] សន្ទានុក្រមភ្ជាប់នឹង ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[3] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩), បកប្រែក្រៅផ្លូវការ អ៊ីវ ប៉ូលី, មាត្រា ២។

លក្ខណៈវិនិច្ឆ័យនេះក៏ទាមទារផងដែរ អោយមានការធ្វើកិច្ចសន្យាស្របទៅតាមទម្រង់ ដែលវិធានអន្តរជាតិតម្រូវ បើមិនដូច្នេះទេ កិច្ចព្រមព្រៀងនោះអាចនឹងគ្មានសុពលភាព។ តាមវិធានច្បាប់អន្តរជាតិ សន្ធិសញ្ញាទាមទារអោយមានការផ្តល់សច្ចាប័ន ឬព្រមព្រៀងដោយរដ្ឋ ទើបមានសុពលភាព ឬចងជាកាតព្វកិច្ចដល់រដ្ឋ។[4]

## កថាខណ្ឌទី២ ប្រភពអន្តរជាតិ

យោងតាម សន្ទានុក្រមច្បាប់ជាភាសាបារាំង Dalloz ឆ្នាំ២០០៧ "សន្ធិសញ្ញា" គឺជា កិច្ចព្រមព្រៀងដែលធ្វើឡើងដោយរដ្ឋ ឬដោយតួអង្គសង្គមនៃនីតិអន្តរជាតិ ក្នុងន័យបង្កើតអានុភាពច្បាប់ នៅក្នុងទំនាក់ទំនងទៅវិញទៅមក។ ការអនុវត្តជាក់ស្តែងពាក្យ សន្ធិសញ្ញា មានសទិសន័យទៅនឹង ពាក្យ អនុសញ្ញា កតិកាសញ្ញា កិច្ចព្រមព្រៀង ពិធីសារ...(International Agreement, Protocol, Covenant, Convention or Exchange of Letter .et.) ។

ចំណែកទ្រឹស្តីវិទូ បានឲ្យនិយមន័យ "សន្ធិសញ្ញា" ថាជាការសម្តែងឆន្ទៈ ដែលផ្តល់ដោយតួអង្គនៃនីតិអន្តរជាតិ (រដ្ឋ និងអង្គការអន្តរជាតិ) ហើយដែលត្រូវមានទិសដៅបង្កើតនូវអានុភាព គតិយុត្ត នៅតាមវិធាននៃនីតិអន្តរជាតិ។

យ៉ាងណាមិញ សន្ធិសញ្ញា ក៏អាចត្រូវបានធ្វើឡើងដោយអង្គការអន្តរជាតិផងដែរ ព្រោះអង្គការអន្តរជាតិ ក៏ជាតួអង្គមួយនៃនីតិអន្តរជាតិ ហើយមានបុគ្គលភាពគតិយុត្តិគ្រប់គ្រាន់ក្នុងការចុះសន្ធិសញ្ញាដូចទៅនឹងរដ្ឋដែរ។ ផងដែរសន្ធិសញ្ញាអាចមានឈ្មោះផ្សេងគ្នា និងចងក្រងឡើយដោយលិខិតតួបករណ៍មួយ ឬច្រើន[5] ។

## កថាខណ្ឌទី៣ សណ្ឋាននៃសន្ធិសញ្ញា

សន្ធិសញ្ញា អាចស្តែងឡើងតាមរូបភាពដូចជា៖

---

[4] មាស បូរ៉ា, នីតិអន្តរជាតិសាធារណៈ, (ភ្នំពេញ, ២០១៣) ទំព័រ៥៣។

[5] Vienna Convention on the Law of Treaties between States and International Organizations or between International Organizations 1986 (អនុសញ្ញាទីក្រុងវីយ៉េន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា រវាង រដ្ឋ និងអង្គការអន្តរជាតិ ឬរវាង អង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ឆ្នាំ១៩៨៦) មាត្រា ២។

១.″កិច្ចព្រមព្រៀងទម្រង់សាមញ្ញ″ សំដៅលើសន្ធិសញ្ញា ដែលពុំឆ្លងកាត់តាមការផ្តល់សច្ចាប័ន។

២.″សន្ធិសញ្ញាទ្វេភាគីធម្មតា″ ជាកិច្ចព្រមព្រៀង ដែលធ្វើឡើងដោយរដ្ឋពីរ។

៣.″សន្ធិសញ្ញាពហុភាគីធម្មតា″ ជាកិច្ចព្រមព្រៀង ដែលធ្វើឡើងដោយរដ្ឋ ចាប់ពីបីឡើងទៅ។

៤.″សន្ធិសញ្ញាពហុភាគីទូទៅ″ ឬហៅម្យ៉ាងទៀតថាជា "អនុសញ្ញាពហុភាគីទូទៅ″ គឺជាសន្ធិសញ្ញាដែលទាក់ទងនឹងវិធានទូទៅនៃនីតិអន្តរជាតិ ឬស្តីពីផលប្រយោជន៍ទូទៅ នៃបណ្តារដ្ឋទាំងមូល [6]។

### កថាខណ្ឌទី៤ ការប្រើប្រាស់ពាក្យពេចន៍

ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ពាក្យពេចន៍គេតែងពើបប្រទះនឹងសំណួរមួយចំនួនថាតើពាក្យ សន្ធិសញ្ញា អនុសញ្ញា និងកតិកាសញ្ញា មានលក្ខណៈខុសគ្នា ឬយ៉ាងណា? នេះជាសំណួរដែលមិន ទាន់មានចម្លើយជាក់លាក់នៅឡើយទេ។ សន្ធិសញ្ញា គឺជាពាក្យទូទៅ។ អនុសញ្ញា ក៏ជាសន្ធិសញ្ញា។ ការប្រើប្រាស់ពាក្យពេចន៍ អាចមិនបង្កប់ន័យសំខាន់នោះទេ ពីព្រោះគ្រាន់តែជាជម្រើសនៃការប្រើប្រាស់។ អ្នកសិក្សាស្រាវជ្រាវ បានផ្តល់ការកត់សម្គាល់ថា កិច្ចព្រមព្រៀង វាជាពាក្យដែលប្រើជាទូទៅសំដៅលើកិច្ច ព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ ។ រីឯពាក្យ Pact ដែលជាកិច្ចព្រមព្រៀងផងដែរនោះ សំដៅលើកិច្ចព្រមព្រៀង រវាងរដ្ឋ និងរដ្ឋ សម្រាប់បញ្ចប់សង្គ្រាម។ ឧទាហរណ៍ peace pact[7]។ ការកត់សម្គាល់ចុងក្រោយក្នុងវិស័យសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ប្រើតែពាក្យអនុសញ្ញា(Convention) ឬកតិកាសញ្ញា (Covenant) តែប៉ុណ្ណោះ។ យ៉ាងខ្លីយើងអាច ធ្វើការកត់សម្គាល់បានថារាល់កិច្ចព្រមព្រៀងទាំងឡាយ ណាដែលធ្វើឡើយដោយតួអង្គនៃនីតិអន្តរជាតិ ផងដែរកិច្ចព្រមព្រៀងនោះ បានគោរពបទដ្ឋានរបស់វិធានអន្តរជាតិ ត្រូវបានចាត់ទុកថាជាសន្ធិសញ្ញាអន្តរជាតិ។ ចំពោះការគូសបន្ទាត់អោយដាច់ លើឈ្មោះនៃសន្ធិសញ្ញាអន្តរជាតិ គួរត្រូវវាបានធ្វើឡើង ដោយផ្អែកទៅលើសណ្ឋាននៃសន្ធិសញ្ញាទើបប្រសើរ។

ពាក្យដទៃទៀតដែលត្រូវបានប្រើជំនួសពាក្យ សន្ធិសញ្ញា៖

1) ធម្មនុញ្ញ(Charter)
2) អនុសញ្ញា(Convention)

[6] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (ភ្នំពេញ, ២០១៨), ទំព័រ២៥។

[7] Bryan A. garner, the Back′s Law Dictionary (Bryan, the Black), 8th ed., p. 1140; for example, the Paris Pact of 1928 on the Banning of War (Kellogg-Briand Pact), see Peter Malanckuz, IL, supra note 1, p. 24.

3) កតិកាសញ្ញា(Pact)

4) ពិធីសារ(Protocol)

5) សេចក្តីប្រកាស(Declaration)

6) អនុស្សារណៈយោគយល់(Memorandum of Understanding) ។ល។

## ផ្នែកទី២៖ ធាតុផ្សំនៃសន្ធិសញ្ញាអន្តរជាតិ ក្នុងន័យទូទៅ

សន្ធិសញ្ញាអន្តរជាតិ ជាសត្យានុម័ត ត្រូវធ្វើឡើយដោយរៀបចំជា ឯកសារជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះហត្ថលេខា ដោយតួអង្គនៃនីតិអន្តរជាតិ ដែលមានកម្មវត្ថុដើម្បីបង្កើតជាអានុភាពគតិយុត្ត និងត្រូវតែចែងឡើង ដោយស្របទៅតាមវិធាននៃនីតិអន្តរជាតិ។

### កថាខណ្ឌទី១៖ ឯកសារជាលាយលក្ខណ៍អក្សរ

សន្ធិសញ្ញា ត្រូវធ្វើឡើយដោយមាននូវសំណេរ នៅក្នុងឯកសារជាក់ស្តែង ដូចជាសៀវភៅ ឬមធ្យោបាយផ្សេងទៀតដូចជា សាត្រាច្បាប់ជាដើម។ យ៉ាងណាមិញ រដ្ឋ ឬអង្គការអន្តរជាតិ អាចធ្វើការព្រមព្រៀងគ្នា ដោយពុំចាំបាច់សរសេរជាលាយលក្ខណ៍អក្សរ លើទម្រង់កិច្ចព្រមព្រៀងនោះ ក៏ប៉ុន្តែក្នុងករណីនេះ គេពុំអាចចាត់ទុកកិច្ចព្រមព្រៀងនោះថាជា សន្ធិសញ្ញាអន្តរជាតិបាននោះទេ។ ឧទាហរណ៍៖ រឿងក្តីនៅចំពោះ មុខតុលាការយុត្តិធម៌អន្តរជាតិ[8] រវាងប្រទេសដាណឺម៉ា(Denmark) និងប្រទេសណ័រវ៉េ (Norway) នៅឆ្នាំ១៩៣៣ ស្តីពីប្រេហ្គាអែនឡែន ខាងកើត East Groendland។ ក្រៅពីនេះគេក៏សង្កេត ឃើញមាន ការករកើត អនុសញ្ញា មិនផ្លូវការជាច្រើន។

### កថាខណ្ឌទី២៖ ធ្វើឡើងដោយអ្នកដែលមានបុគ្គលភាពគតិយុត្ត

មានតែតួអង្គនៃនីតិអន្តរជាតិ(រដ្ឋ អង្គការអន្តរជាតិ និងបុរីវ៉ាទីកង់) ប៉ុណ្ណោះដែលមានសមត្ថកិច្ច ក្នុងការចុះកិច្ចព្រមព្រៀង ហើយអាចចាត់ទុកថាជាសន្ធិសញ្ញាអន្តរជាតិបាន។ កាលណាបើរដ្ឋបានចុះកិច្ច ព្រមព្រៀងជាមួយបុគ្គលឯកជន គេហៅកិច្ចព្រមព្រៀងនេះថាជាកិច្ចព្រមព្រៀងពហុជាតិ។ កិច្ចព្រមព្រៀងពហុជាតិនេះ ទាក់ទងនឹងក្រុមហ៊ុនពហុជាតិ ដែលធ្វើធុរៈកិច្ចនៅក្រៅប្រទេស ហើយប្រភេទគតិយុត្តរបស់វា គឺគ្រាន់តែជា កិច្ចសន្យាសាមញ្ញប៉ុណ្ណោះ។

[8] Permanent Court of Justice: PCIJ

**កថាខណ្ឌទី៣៖ មានគោលដៅបង្កើតអានុភាពគតិយុត្ត**

អានុភាពគតិយុត្តនេះ សំដៅលើការបង្កើតសិទ្ធិ និងកាតព្វកិច្ច នៅលើតួរអង្គនៃនីតិ។ និយាយធ្វើការ បកស្រាយដូច្នេះបានដោយសារថា សន្ធិសញ្ញាខ្លះ ពុំបានបង្កើតអោយមាននូវអានុភាពគតិយុត្តនោះទេ។ ឧទាហរណ៍ទី១៖ "Gentlemen's Agreement" គឺជាកិច្ចព្រមព្រៀងដែលមានលក្ខណៈ នយោបាយ ពោលគឺវាគ្រាន់តែ បង្ហាញនូវចំណង់ចង់ដើរតាមបន្ទាត់នយោបាយណាមួយ ដែលចេញពីកិច្ចព្រមព្រៀងនោះ។ ឧទាហរណ៍ទី២៖ ធម្មនុញ្ញអាតាឡង់ទិក ឆ្នាំ១៩៤១ -កិច្ចបញ្ចប់សន្និសិទ្ធិស្តីពីសន្តិសុខ និង សហប្រតិបត្តិការអឺរ៉ុបនៅហែលស៊ីនគី (Helsinki) ឆ្នាំ១៩៧៥ និងការបន្តកិច្ចនេះ នៅឆ្នាំ១៩៩០ ដោយ ធម្មនុញ្ញក្រុងប៉ារីស សម្រាប់អឺរ៉ុបថ្មីមួយ -សេចក្តីថ្លែងការណ៍រួមដែលបានមកពីជំនួបពិភាក្សារវាង អ្នកនយោបាយនៃរដ្ឋពីរ ឬច្រើន (រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ បានជួបប្រជុំពិភាក្សាគ្នាពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០១ បានចេញសេចក្តីថ្លែងការណ៍រួម ស្តីពីការរៀបចំបោះបង្គោលព្រំដែន និងការទទួលស្គាល់លិខិតឆ្លងដែនការទូតរបស់ប្រទេសទាំង២)[9]។

**កថាខណ្ឌទី៤៖ កិច្ចព្រមព្រៀងត្រូវចែងដោយនីតិអន្តរជាតិ**

កិច្ចព្រមព្រៀងរដ្ឋ ឬរវាងអង្គការអន្តររដ្ឋាភិបាល ត្រូវតែចែងដោយនីតិអន្តរជាតិ ដូចជាករណីព្រំប្រទល់ ឬករណីអនុប្បទានទឹកដីជាដើម។

ក៏ប៉ុន្តែរដ្ឋ ឬអង្គការអន្តរជាតិនេះ អាចសំរេចជ្រើសរើសយកច្បាប់ណាមួយមកអនុវត្តចំពោះ កិច្ចព្រម ព្រៀងរបស់ខ្លួនបាន។ នៅក្នុងករណីនេះ គេមិនហៅថាសន្ធិសញ្ញាអន្តរជាតិទេ តែជាកិច្ចសន្យា(contract) មួយទៅវិញ។

## ផ្នែកទី៤៖ វិធាននៃនីតិអន្តរជាតិ

វិធានអន្តរជាតិ ជាវិធានទំនៀមទំលាប់អស់រយៈពេលជាយូរ មុននឹងត្រូវបានចងក្រងវាចេញជានីតិពិតប្រាកដ។ កិច្ចការចងក្រងជាវិធានពិតប្រាកដ នេះគឺជាបន្ទុករបស់គណៈកម្មការនីតិអន្តរជាតិ ដែលជាអ្នករៀបចំប្រមូលផ្តុំវិធានអន្តរជាតិ និងបានជម្រុញអោយមានការកកើតនូវអនុសញ្ញាអន្តរជាតិ ដែលមានចំណងជើងថា "នីតិ

[9] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ២៧។

សន្ធិសញ្ញា"[10] បន្ទាប់ពីមានការប្រព្រឹត្តទៅនៃសន្និសិទ្ធិចំនួន២លើក នៅទីក្រុងវីយែន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩។ ត្រូវកំណត់សម្គាល់ផងដែរថា អនុសញ្ញានេះចែងតែអំពីសន្ធិសញ្ញារវាងរដ្ឋ និងរដ្ឋ ប៉ុណ្ណោះដោយទុកដោយឡែកនូវបញ្ហា ដែលទាក់ទងនឹងសន្ធិសញ្ញាពិសេសមួយចំនួនដូចជា សន្ធិសញ្ញាស្តីពី ការបន្តវេននៃរដ្ឋ សន្ធិសញ្ញាស្តីពីខនៃប្រជាជាតិដែលត្រូវអនុគ្រោះបំផុត ឬសន្ធិសញ្ញទាក់ទងនឹងការទទួលខុសត្រូវរបស់រដ្ឋ ឬផលវិបាកសង្គ្រាម។

អនុសញ្ញាទីក្រុងវីយែនស្តីពីនីតិសន្ធិសញ្ញា ចុះនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ ដែលមានតែ៨៥ មាត្រា បានចែងអំពីការតាក់តែងការអនុវត្តសន្ធិសញ្ញា ការធ្វើវិសោធនកម្មលើសន្ធិសញ្ញា និងការផុតរលត់នៃ សន្ធិសញ្ញាដែលធ្វើឡើងរវាងរដ្ឋ និងរដ្ឋ។ ហើយអនុសញ្ញានេះបានចូលជាធរមាននៅឆ្នាំ១៩៨០[11]។ ក្រៅពីនេះ មានអនុសញ្ញាទីក្រុងវីយែន ស្តីពីការបន្តវេននៃរដ្ឋក្នុងការគោរពសន្ធិសញ្ញា ដែលចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨ និងចូលជាធរមាននៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៦[12]។ ជាចុងក្រោយនៅមានអនុសញ្ញាមួយទៀត ដែលចែងអំពីសន្ធិសញ្ញារវាងរដ្ឋ និងអង្គការអន្តជាតិ ឬរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ដែលធ្វើឡើងនៅទីក្រុងវីយែនដែរ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ១៩៨៦ តែមិនទាន់ចូលជាធរមាននៅឡើយទេ។ [13]

[10] Law Of Treaties។

[11] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩)។

[12] United Nations Treaty Collections។

[13] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ២៧។

## ផ្នែកទី៥៖ សន្ធិសញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងតួអង្គនានានៃនីតិអន្តរជាតិ

យោងគេហទំព័រផ្លូវការ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបង្ហាញអោយ ឃើញថា ព្រះរាជាណាចក្រកម្ពុជាមានសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ មានចំនួន១៥៦[14]។ ចំណែកឯ ឯកសារសន្ធិសញ្ញាពហុភាគី ដែលមានកម្ពុជាជាភាគី ហើយបានតម្កល់ទុកនៅ អង្គការសហប្រជាជាតិមាន ចំនួន១៨៦[15]។

[14] https://www.mfaic.gov.kh/Archive/Treaty%20and%20Agreement

[15] https://treaties.un.org/Pages/Result.aspx?tab=UN&searchText=cambodia&dir=Publication/MTDSG&query=All

# ជំពូកទី២
# ការរៀបចំធ្វើសន្ធិសញ្ញាអន្តរជាតិ

ក្នុងដំណើរការក៏ដូចជាការប្រព្រឹត្តទៅនៃការរៀបចំធ្វើសន្ធិសញ្ញា ការចងក្រងទាំងនោះ ត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌចំនួនពីរ៖ ដែលទីមួយ ជាល័ក្ខខ័ណ្ឌទម្រង់ និងទីពីរ ជាល័ក្ខខ័ណ្ឌគ្រឹះ ដើម្បីអោយមានសុពលភាព ហើយមានអានុភាពអាចអនុវត្តបាន។

## ផ្នែកទី១ ល័ក្ខខ័ណ្ឌទម្រង់

សន្ធិសញ្ញា មានទម្រង់ផ្សេងៗគ្នាជាច្រើនដូចជា៖ សន្ធិសញ្ញាដែលមានទម្រង់ទូទៅ(១) អនុសញ្ញាពហុភាគី(២) សន្ធិសញ្ញាដែលមានទម្រង់សាមញ្ញ(៣) និងសន្ធិសញ្ញាដែលធ្វើឡើងដោយអង្គការអន្តរជាតិ ដែលហៅថាសន្ធិសញ្ញារវាងអង្គការអន្តរជាតិ(៤)។ សន្ធិសញ្ញាទាំងនេះមានខ្លះជា សន្ធិសញ្ញាទ្វេភាគី និងខ្លះទៀតជាសន្ធិសញ្ញាពហុភាគី។

### កថាខណ្ឌទី១ សន្ធិសញ្ញាក្នុងន័យទូទៅ

ជាកិច្ចព្រមព្រៀងទាំងឡាយ ដែលមានទម្រង់ឱឡារឹក និងត្រូវចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬ ដោយអាជ្ញាធរដែលទទួលបានសិទ្ធិចុះហត្ថលេខា ដោយពេញលក្ខណៈច្បាប់។ សន្ធិសញ្ញាប្រភេទនេះ ត្រូវធ្វើឡើងដោយឆ្លងកាត់ដំណាក់កាលចំនួនបីធំៗគឺ៖ (១)ការចរចា (២)ការចុះហត្ថលេខា និង(៣)ការ ផ្តល់សច្ចាប័ន។

#### ១.ការចរចា

##### ១.១ អ្នកដែលមានសមត្ថភាពចរចា

បុគ្គលដែលមានសមត្ថភាពក្នុងការចរចាធ្វើសន្ធិសញ្ញារួមមាន៖ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស និងប្រមុខបេសកកម្មការទូត។[16] ផងដែរក្នុងករណី ដែលអ្នកខាងលើ ពុំអាចបំពេញមុខងារដោយផ្ទាល់បាន ក៏នៅមានតំណាងពេញសមត្ថកិច្ច (បុណ្ណទុត) ដែលតម្រូវអោយ មាននូវលិខិតប្រគល់សិទ្ធិប្រទាន ពីសំណាក់អាជ្ញាធរ ដូចដែល មានលើកឡើងខាងលើ (ប្រមុខរដ្ឋ ជាដើម)។ [17]

[16] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩), បកប្រែក្រៅផ្លូវការ អ៊ីវ ប៉ូលី, មាត្រា ៧។

[17] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ២៩-៣០។

### ១.២ គ្រប់ខ័ណ្ឌនៃការជជែកពិភាក្សា

ការចរចារ ត្រូវបានធ្វើឡើងតាមច្រើនរបៀបដូចជា៖ ការជជែកតាមផ្លូវការទូត សន្និសិទ្ធិពិសេស ឬការចរចាដែលធ្វើឡើងនៅក្នុងអង្គការអន្តរជាតិណាមួយ ឬតាមការកោះអញ្ជើញ ដោយអង្គការអន្តរជាតិណាមួយ។

### ១.៣ ការតាក់តែងអត្ថបទនៃសន្ធិសញ្ញា

ភាគីត្រូវធ្វើការចូលរួមចរចា ធ្វើសំណើរលើខ្លឹមសារនៃកិច្ចព្រមព្រៀង ប្រសិនបើភាគីណាមួយ មិនយល់ព្រមលើសំណើរនេះ គាត់អាចស្នើសុំអោយមាន ការកែប្រែអត្ថបទដែល ស្នើរឡើងនោះបាន។ គេត្រូវធ្វើការបោះឆ្នោតដើម្បីសម្រេចយកសំណើណាមួយ។ បច្ចុប្បន្នកាលគេ និយមប្រើប្រាស់វិធី បោះឆ្នោតសម្រេចដោយយកសម្លេងភាគច្រើន ដែលខុសប្លែកពីមុន គេភាគច្រើនប្រើការបោះឆ្នោត សម្រេចដោយយកសម្លេងឯកច្ឆន្ទ (Unanimity)។

ក្នុងការតាក់តែងអត្ថបទនេះ ភាគីច្រើនគេនិយមប្រើប្រាស់ភាសាផ្លូវការ របស់អង្គការសហប្រជាជាតិ (ដូចជាភាសាបារាំង ភាសាអង់គ្លេស) និងភាសា របស់ភាគីដែលពាក់ព័ន្ធ។ ក៏ប៉ុន្តែបើជាសន្ធិសញ្ញាពហុភាគីវិញ គេប្រើភាសាផ្លូវការរបស់អង្គការសហប្រជា ជាតិ។

ជាគោលការណ៍ សន្ធិសញ្ញាមានទម្រង់ដូចតទៅ៖ បុព្វកថា តួនៃសន្ធិសញ្ញា និង ឧបសម្ព័ន្ធ។

1. បុព្វកថា៖ គឺជាតួដើមនៃសន្ធិសញ្ញាដែលមានចែងនូវឈ្មោះរបស់ភាគី នៃសន្ធិសញ្ញា មូលហេតុ និងគោលបំណងនៃសន្ធិសញ្ញា ព្រមទាំងឈ្មោះរបស់បុណ្ណទូត។
2. តួនៃសន្ធិសញ្ញា៖ មានចែងនូវមាត្រាផ្សេងៗ របស់សន្ធិសញ្ញាព្រមទាំងសារវន្តបញ្ញត្តិ ដើម្បីសម្តែងនូវរបបគតិយុត្តិនៃអនុសញ្ញា ក៏ដូចជាការចូលជាធរមាន ការផ្តល់សច្ចាប័ន រយៈពេល ការដាក់តម្កល់ដំណោះស្រាយជម្លោះ។ល។
3. ឧបសម្ព័ន្ធ៖ គឺជាបញ្ញត្តិ ដែលទាក់ទងនឹងបច្ចេកទេស ឬសម្រាប់បន្ថែម ហើយបញ្ញត្តិ នេះ មានតម្លៃគតិយុត្តដូចគ្នានឹងសន្ធិសញ្ញាខ្លួនឯងដែរ។

### ២. ការចុះហត្ថលេខាលើសន្ធិសញ្ញា

ជាដំណាក់កាលមួយ បញ្ជាក់ពីការបញ្ចប់នូវការចរចា តែមិនមែនជាការធ្វើអោយសន្ធិសញ្ញាមានអានុភាពបង្ខំនោះទេ លើកលែងតែសន្ធិសញ្ញាមានទម្រង់សាមញ្ញ។ នៅពេលចុះហត្ថលេខារួច អត្ថបទមិនត្រូវបានកែប្រែទៀតឡើយ ការចុះហត្ថលេខាផ្តល់នូវយថាភាព ដល់អត្ថបទនៃសន្ធិសញ្ញា ពោលគឺជាការសំដែងនូវការទទួលស្គាល់ដល់ការយល់ព្រមរបស់ភាគីហត្ថលេខី ដែលធ្វើឡើងដោយ ប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីការបរទេស ឬបុណ្ណទូតលើសន្ធិសញ្ញា។ ដំណាក់កាលនៃការចុះហត្ថលេខានេះ ត្រូវកត់ត្រាផងដែរនូវទីកន្លែង និងកាលបរិច្ឆេទនៃសន្ធិសញ្ញា។[18]

ការចុះហត្ថលេខា លើសន្ធិសញ្ញាអន្តរជាតិ អាចធ្វើឡើងដោយៈ

1) អ្នកដែលមានអំណាចចុះហត្ថលេខា ដូចជាប្រធានាធិបតី នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស។
2) អ្នកដែលទទួលបាននូវសិទ្ធិប្រទាន (បុណ្ណទូត) ដែលទទួលបាននូវប្រតិភូកម្មហត្ថលេខា ហើយអាចចុះហត្ថលេខា ក្នុងនាមអោយរដ្ឋាភិបាលរបស់ខ្លួនតែម្តង។
3) អ្នកដែលទទួលបាននូវសិទ្ធិចុះហត្ថលេខាសង្ខេប ត្រូវរង់ចាំការចុះហត្ថលេខាបង្ហើយរបស់ អ្នកដែលមានអំណាចចុះហត្ថលេខា ដូចជា ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល។
4) រដ្ឋហត្ថលេខីលើសន្ធិសញ្ញាអន្តរជាតិ មិនទាន់មានកាតព្វកិច្ចគោរពសន្ធិសញ្ញានោះទេ តែសហគមន៍អន្តរជាតិ តម្រូវអោយភាគីហត្ថលេខី កុំរំលោភបំពានលើកម្មវត្ថុ និងបទបញ្ញត្តិនៃសន្ធិ សញ្ញានោះ។

### ៣. ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ

គឺជាការយល់ព្រមលើសន្ធិសញ្ញា ដោយអង្គការរបស់រដ្ឋ ដែលមានសមត្ថកិច្ចដើម្បីអោយរដ្ឋជាប់ជាកិច្ចសន្យាជាលក្ខណៈអន្តរជាតិបាន។

ក្រោយពីការចរចា និងការចុះហត្ថលេខាដោយអាជ្ញាធរមានសមត្ថកិច្ចរួចមក សន្ធិសញ្ញាត្រូវឆ្លងកាត់កិច្ចមួយទៀត ដើម្បីអោយរដ្ឋហត្ថលេខីជាប់ជាកិច្ចសន្យាជាលក្ខណៈអន្តរជាតិ ជាមួយនឹងសន្ធិសញ្ញានេះ។ ពោលគឺអាជ្ញាធរផ្ទៃក្នុងមានសមត្ថកិច្ចផ្តល់សច្ចាប័ទៅលើសន្ធិសញ្ញានេះ ដោយមានភ្ជាប់ជាមួយនូវកិច្ចជាឱឡារឹកមួយបន្ថែម ដើម្បីបញ្ជាក់ពីការភ្ជាប់ខ្លួនរបស់រដ្ឋនោះ ទៅនឹងសន្ធិសញ្ញាណាមួយ។ ជាក់ស្តែងនៅក្នុងព្រះរាជាណា

[18] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៣១-៣២។

ចក្រកម្ពុជា រដ្ឋសភាអាចអនុម័តយល់ព្រម ឬលុបចោលនូវសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ[19] បាន។ ហើយបន្ទាប់ពីការអនុម័តរបស់ រដ្ឋសភា ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខា ដើម្បីផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ[20] និងនៅចុងបញ្ចប់លិខិតតូបករណ៍ ដែលបញ្ជាក់ថាកម្ពុជាព្រមផ្តល់សច្ចាប័ន ត្រូវផ្ញើរទៅកន្លែងដាក់តម្កល់ សន្ធិសញ្ញានៅអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ។ ចំពោះប្រទេសបារាំង គឺប្រធានាធិបតី ជាអ្នកសម្រេចផ្តល់សច្ចាប័នដល់សន្ធិសញ្ញា ដោយមានការចុះហត្ថលេខាបន្ថែម ដោយនាយករដ្ឋមន្ត្រី។ ចំពោះសហរដ្ឋអាមេរិកវិញ គឺព្រឹទ្ធសភារបស់ប្រទេសនេះ ដែលជាអ្នកមានសមត្ថកិច្ចផ្តល់សច្ចាប័ន ដោយធ្វើការបោះឆ្នោតយកសម្លេងភាគច្រើន ២/៣ (supermajority)។

លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ត្រូវប្រគល់ជូនទៅភាគីម្ខាងទៀត (ចំពោះអនុសញ្ញា ទ្វេភាគី)និងត្រូវដាក់តម្កល់(ចំពោះសន្ធិសញ្ញាពហុភាគី) នៅក្នុងរដ្ឋណាមួយ ឬក្នុងអង្គការអន្តរ ជាតិណាមួយ។

ការផ្តល់សច្ចាប័ន គឺជាការកំណត់ថា រដ្ឋណាមួយបានក្លាយជាភាគីរបស់ សន្ធិសញ្ញាណាមួយ[21]។ ក្នុងករណីការផ្តល់សច្ចាប័នមិនត្រឹមត្រូវ សន្ធិសញ្ញានឹងត្រូវចាត់ទុកជាមោឃៈបាន តែប្រសិនបើ អនិតយភាព នៃសន្ធិសញ្ញាធ្វើឡើងនៅលើខ្លឹមសារជាក់ស្តែង[22] ដូចជា៖ ការរំលោភ ដ៏ជាក់លាក់លើបទបញ្ញត្តិនៃច្បាប់ផ្ទៃក្នុង ដែលជាវិធានជាមូលដ្ឋាននៃច្បាប់នេះ។ ការផ្តល់សច្ចាប័ន គឺជាកិច្ចឆន្ទានុសិទ្ធិរបស់រដ្ឋ ពោលគឺរដ្ឋមានសេរីភាពគ្រប់គ្រាន់ក្នុងការបំពេញកិច្ចនេះ។ ប្រសិនបើរដ្ឋ បដិសេធមិនព្រមផ្តល់សច្ចាប័ននោះទេ រដ្ឋនឹងពុំមានការទទួលខុសត្រូវអ្វីទាំងអស់ ក៏ប៉ុន្តែរដ្ឋនោះអាចទទួលរងនូវផលវិបាកផ្នែកនយោបាយ ឬក៏ការគាប់សង្កត់ខាងផ្នែកសេដ្ឋកិច្ចផ្សេងៗ។ ឧទាហរណ៍៖ សហរដ្ឋអាមេរិក បានបដិសេធ មិនព្រមផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញា ទីក្រុងវ៉ែកសៃ(Versailles) ។ ប្រទេស បារាំង មិនព្រមផ្តល់សច្ចាប័ន ចំពោះសហគមន៍អឺរ៉ុប។

### កថាខណ្ឌទី២៖ អនុសញ្ញាពហុភាគីទូទៅ

សន្ធិសញ្ញាពហុភាគីទូទៅ គឺជាកិច្ចព្រមព្រៀង ដែលធ្វើឡើងដោយភាគីជាច្រើន ពោលគឺរាល់សន្ធិសញ្ញាទាំងឡាយណាដែលមានសមាជិកភាពចាប់ពីបីឡើងទៅ យើងអាចហៅថាសន្ធិសញ្ញាពហុភាគី។ អនុសញ្ញាពហុ

[19] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៩០.៥។

[20] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា២៦។

[21] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវ៉ៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩, មាត្រា ២៤។

[22] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវ៉ៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩, មាត្រា ៤៦។

ភាគី ក៏ជាសន្ធិសញ្ញាពហុភាគីដែរ តែគ្រាន់តែការដាក់ឈ្មោះថា អនុសញ្ញាពហុភាគីទូទៅនេះ គឺដើម្បីកត់សម្គាល់សន្ធិសញ្ញា ដែលចែងអំពីនីតិអន្តរជាតិទូទៅ។

អនុសញ្ញាពហុភាគីទូទៅ សំដៅលើសន្ធិសញ្ញាទាំងឡាយ ដែលចែងអំពីវិធាននៃនីតិអន្តរជាតិ។ ឧទាហរណ៍ៈ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត, អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៣ ស្តីពីទំនាក់ទំនងកុងស៊ុល, អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីនីតិសន្ធិសញ្ញា, អនុសញ្ញាម៉ុងតេហ្គូប៉ៃ ឆ្នាំ១៩៨២ ស្តីពីនីតិសមុទ្ទ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៨៩៩ ដល់ឆ្នាំ ១៩០៧ ស្តីពីច្បាប់ និង ទំនៀម ទម្លាប់សង្គ្រាម។ល។[23]

អនុសញ្ញាប្រភេទនេះពុំត្រូវបានចែង ដោយវិធានពិសេសនៅក្នុងទីក្រុងវីយែនឆ្នាំ ១៩៦៩ ឡើយ។ ក៏ប៉ុន្តែអនុសញ្ញាពហុភាគីទូទៅនេះ មានលក្ខណៈដោយឡែកខ្លះ ដូចជាល័ក្ខខ័ណ្ឌនៃការតាក់តែង ល័ក្ខខ័ណ្ឌ នៃការចូលរួមខដាក់ល័ក្ខខ័ណ្ឌ និងខដែន។

### ១. ល័ក្ខខ័ណ្ឌនៃការតាក់តែង

ការតាក់តែងអត្ថបទនៃអនុសញ្ញាត្រូវធ្វើឡើង ឬមួយក្នុងក្របខណ្ឌនៃសន្និសីទអន្តរជាតិ ឬមួយក្នុងក្របខ័ណ្ឌនៃអង្គការអន្តរជាតិណាមួយ។ តាមធម្មតាការចូលរួមរបស់រដ្ឋ ក្នុងការតាក់ តែងអត្ថបទ អនុសញ្ញាមានការប្រែប្រួលទៅតាមកម្មវត្ថុ នៃកិច្ចព្រមព្រៀង និងការចង់បានអោយមានការចូលរួម ជាលក្ខណៈសកលនៃសំណាក់រដ្ឋក្រោមការឧបត្ថម្ភ របស់អង្គការសហប្រជា ជាតិ។

ការសម្រេចយកអត្ថបទណាមួយ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើនធម្មតា ៥០+១ ឬដោយសម្លេងភាគច្រើនលើសលុប ២/៣ នៃរដ្ឋដែលបានចូលរួម និងបោះឆ្នោត។ តែអាចសម្រេចតាមបែបផ្សេង ឬតាមការចង់បានរបស់ភាគី។

យថាភាពនៃកិច្ចព្រមព្រៀង ត្រូវធ្វើឡើងដោយការចុះហត្ថលេខាសង្ខេប ឬការចុះហត្ថលេខា របស់គណៈប្រតិភូ ឬក្នុងសេចក្តីថ្លែងការណ៍ ឬនៅក្នុងកិច្ចបញ្ចប់ជាដើម។ ហត្ថលេខាលើកិច្ចព្រមព្រៀង អាចធ្វើឡើងក្នុងពេលតែមួយ ឬក្នុងពេលបន្តបន្ទាប់គ្នា នៅក្រុងច្រើនផ្សេងគ្នា ដោយមានការគ្រោងទុកជាមុន។

[23] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ ៣២-៣៥។

## ២. ល័ក្ខខ័ណ្ឌនៃការចូលរួម

អនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦៩ ពុំបានចែងអំពីសកលភាពនៃការចូលរួមរបស់រដ្ឋ ក្នុងអនុសញ្ញាពហុភាគីទូទៅឡើយ។ ចំពោះអនុសញ្ញាពហុភាគីមិនទូទៅ ត្រូវមានការយល់ព្រមពីអ្នក ដែលមានគំនិតផ្តួចផ្តើម។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង គេតែងតែបើកចំហចំពោះរដ្ឋទាំងអស់។

រដ្ឋអាចចូលជាសមាជិក អនុសញ្ញាពហុភាគីបានតាមនីតិវិធិច្រើនយ៉ាង ដូចជារដ្ឋអាចចុះហត្ថលេខា ភ្លាមៗតាំងពីដើមទី ឬចុះហត្ថលេខានៅពេលអត្ថបទរបស់អនុសញ្ញា ត្រូវតាក់តែងចប់ជាស្ថាពរ (ក្នុងករណីអនុសញ្ញានេះជាអនុសញ្ញាបើកចំហ) ឬតាមការសុំចូលជាសមាជិក។ នីតិវិធីចុងក្រោយនេះ គឺជាកិច្ចឯកតោភាគីរបស់រដ្ឋណាមួយក្រោមការធ្វើសេចក្តីសម្រេចប្រកាស សុំភ្ជាប់ខ្លួនទៅនឹងកិច្ចព្រមព្រៀងណាមួយ ស្របតាមខ្លឹមសារអត្ថន័យនៃខរបស់កិច្ចព្រមព្រៀងនោះ។ សេចក្តីប្រកាសចូលរួម នេះពុំមានចុះហត្ថលេខាទេ តែជួនកាលមានការផ្តល់ សច្ចាប័នតែម្តង។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ហៅកិច្ចសុំចូលជាសមាជិក ដែលរង់ចាំការផ្តល់សច្ចាប័នថាជា សេចក្តីប្រកាសសាមញ្ញ។ ក្នុងករណីនេះ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ បង្ខំអោយរដ្ឋមានបំណងសុំនេះ ជៀសវាងរាល់ការប្រព្រឹត្តអំពើណា ដែលផ្ទុយពីគោលបំណងរបស់អនុសញ្ញាដែលខ្លួនសុំចូលរួម។ ឧទាហរណ៍៖ កម្ពុជា សុំចូលជាសមាជិកអង្គការពាណិជកម្មពិភពលោក WTO នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ហើយផ្តល់សច្ចាប័ននៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ ហើយអង្គការនេះសម្រេចអោយ កម្ពុជា ក្លាយជាសមាជិកពេញសិទ្ធិនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។[24]

## ៣. ការចូលជាធរមាននៃអនុសញ្ញាពហុភាគីទូទៅ

ល័ក្ខខ័ណ្ឌអាចមានចែង នៅក្នុងកិច្ចព្រមព្រៀងតែម្តង។ ឧទាហរណ៍ដូចជា សន្ធិសញ្ញាទីក្រុមរ៉ូម ដែលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងក្នុងមាត្រា១២៦ ថាសន្ធិសញ្ញនេះនឹងចូលជាធរមាននៅថ្ងៃទី៦០ បន្ទាប់ពីមានការផ្តល់សច្ចាប័នទី៦០។ អនុសញ្ញាខ្លះទាមទារនូវចំនួនរដ្ឋ ដែលផ្តល់សច្ចាប័ន ឬជួនកាលទាមទារនូវការផ្តល់សច្ចាប័នរបស់ប្រទេសដែលទាក់ទង (គឺនិយាយ អំពីតួនាទីរបស់រដ្ឋនោះ) ដើម្បីអោយអនុសញ្ញានោះចូលជាធរមានបាន។ ត្រង់ចំណុចនេះយើងសន្មត់ថា វាជាវត្ថុមួយយ៉ាងពិតប្រាកដ។ ឧទាហរណ៍៖ សន្ធិសញ្ញា ស្តីពីការហាមប្រាមទាំងស្រុងនូវការធ្វើ សាកល្បងអាវុធនុយក្លេអ៊ែរ២៩ ត្រូវការផ្តល់សច្ចាប័ន៤៤ ពីសំណាក់រដ្ឋដែល មានអាវុធ

[24] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៣៧-៤២។

នុយក្លែអ៊ែរ ដើម្បីអោយវាចូលជាធរមានបាន។ ជួនកាលទៀត គេកំណត់ចំនួនហើយ ថែមទាំងកំណត់កាល បរិច្ឆេទណាមួយទៀត ដើម្បីអោយសន្ធិសញ្ញាអាចចូលជាធរមានបាន។

## ៤. ខដាក់ល័ក្ខខ័ណ្ឌ

ដាក់ល័ក្ខខ័ណ្ឌ (Reservations) គឺជាសេចក្ដីប្រកាសជាឯកតោភាគី ដែលធ្វើបដិប្បញ្ញត្តិ ចំពោះការតាំងបទបញ្ញាក្នុងអនុសញ្ញាណាមួយ។ ខនេះធ្វើអោយរដ្ឋភាគី ដែលចងភ្ជាប់ខ្លួនទៅនឹង សន្ធិសញ្ញាណាមួយ ដែលមានមាត្រាមួយចំនួននៃសន្ធិសញ្ញាប្រឆាំងនឹងច្បាប់ ឬទំនៀមទំលាប់ របស់ខ្លួនអាចក្លាយជាសមាជិកនៃ សន្ធិសញ្ញានេះបាន ដោយមានកែប្រែនូវតម្លៃគតិយុត្តនៃបញ្ញត្តិទាំងនោះ ឬអាចគេចផុតពីការអនុវត្ត បញ្ញត្តិនោះបាន។ ឧទាហរណ៍៖ ICJ, Continental shelf of the Aegean Sea (Greece v. Turkey), judgment of 19 December 1978 ។

### ៤.១ សុពលភាពនៃខដាក់ល័ក្ខខ័ណ្ឌ

ចំពោះសន្ធិសញ្ញាទ្វេភាគី ខដាក់ល័ក្ខខ័ណ្ឌអាចធ្វើឡើង តែនៅពេលចុះហត្ថលេខា ប៉ុណ្ណោះ។ ចំពោះសន្ធិសញ្ញាពហុភាគីវិញ ខដាក់ល័ក្ខខ័ណ្ឌ អាចធ្វើឡើងទាំងពេលចុះហត្ថលេខា ឬនៅពេលផ្ដល់សច្ចាប័ន (ឬនៅពេលយល់ព្រម ឬនៅពេលសុំចូលជាសមាជិក)។ គោលដៅដែលគេយល់ព្រមនូវខដាក់ល័ក្ខខ័ណ្ឌ គឺដើម្បីធ្វើយ៉ាងណាអោយមានការចូលរួម អោយបានច្រើនពីសំណាក់រដ្ឋទាំងឡាយណា នៅក្នុងសន្ធិសញ្ញាពហុភាគី។

ខដាក់ល័ក្ខខ័ណ្ឌមួយ អាចមានសុពលភាពលុះណាវាបានគោរពល័ក្ខខ័ណ្ឌដូចតទៅ៖

1) ខនេះ មិនត្រូវបានហាមឃាត់ដោយអនុសញ្ញា ដែលត្រូវចុះហត្ថលេខា ឬផ្ដល់សច្ចាប័ន ឬផ្ដល់ការយល់ព្រមនោះ។ ការហាមឃាត់នេះដូចមានចែងនៅក្នុង មាត្រា១៩ នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ គឺទី១- សន្ធិសញ្ញាហាមមិនឲ្យមាន ខដាក់ល័ក្ខខ័ណ្ឌនោះ។ ទី២- ខដាក់ល័ក្ខខ័ណ្ឌ ដែលរដ្ឋធ្វើពុំស្ថិតនៅក្នុងចំណោមខដាក់ល័ក្ខខ័ណ្ឌ ដែលប៉ះពាល់ដល់កម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញា។
2) ខនេះ មិនត្រូវផ្ដាច់អនុសញ្ញាចេញពីគោលបំណង និងកម្មវត្ថុរបស់វាទេ[25]។ បញ្ហាដែលចោទឡើង គឺថាតើមានស្ថាប័នណាមួយ ដែលជាអ្នកវាយតម្លៃសុពលភាពរបស់ ខដាក់ល័ក្ខខ័ណ្ឌនេះ។ ជាគោលការណ៍ គ្មានស្ថាប័នណាមួយទេ តែគេអាចសួរយោបល់ពិគ្រោះទៅតុលាការយុត្តិធម៌អន្តរជាតិ ICJ បាន ឬទៅអង្គការ

[25] ICJ, Advisory Opinion and Orders on Reservations to the Convention on the Prevention and Punishment of the crime of Genocide of 28 May 1951.

ទទួលបន្ទុកឃ្លាំងមើលការអនុវត្តសអនុសញ្ញាបាន (ឧទាហរណ៍៖ តុលាការសិទ្ធិមនុស្សអឺរ៉ុបស្តីពីអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប)។

3) ខដាក់ល័ក្ខខ័ណ្ឌ ដែលធ្វើឡើងត្រូវធ្វើដោយមាការយល់ព្រមពីសំណាក់សមាជិកដ៏ទៃទៀត។

### ៤.២ អានុភាពនៃខដាក់ល័ក្ខខ័ណ្ឌ

ខដាក់ល័ក្ខខ័ណ្ឌ ត្រូវគោរពវិធានបីយ៉ាង គឺវិធានទំនាក់ទំនងវិធាននៃខ្លឹមសារទាំងមូល នៃសន្ធិសញ្ញា និងវិធាននៃអនុភាពបដិការ។

ខដាក់ល័ក្ខខ័ណ្ឌ ត្រូវបង្កើតអានុភាពគតិយុត្តតែរវាងភាគី ដែលដាក់ខនេះ និងភាគីដែល យល់ព្រមលើការដាក់ខនេះ ពោលគឺអនុសញ្ញាអាចចូលជាធរមានរវាងភាគី ទាំងពីរនេះប្រសិន បើគ្មានការជំទាស់ក៏ដោយ។ នេះជាការបញ្ជាក់ពីការប្រឆាំង នឹងការដាក់ខដាក់ល័ក្ខខ័ណ្ឌ។ ការប្រឆាំងនេះគ្រាន់តែកំណត់កម្រិតនូវការអនុវត្តបញ្ញត្តិនេះប៉ុណ្ណោះ។

រដ្ឋដែលសុំចូលជាសមាជិកតាមក្រោយ ក្នុងសន្ធិសញ្ញាណាមួយត្រូវតែទទួលយល់ព្រម ទាំងខដាក់ល័ក្ខខ័ណ្ឌ ដែលមានពីមុនមកជាស្រេច។ រដ្ឋដែលបានយល់ព្រម លើខដាក់ល័ក្ខខ័ណ្ឌ ដែលធ្វើឡើងដោយរដ្ឋមួយអាចសំអាងលើខដាក់ល័ក្ខខ័ណ្ឌនេះ ដើម្បីឲ្យរដ្ឋនេះ ព្រមអនុវត្តខនេះចំពោះខ្លួនដែរ[26]។ ក៏ប៉ុន្តែគេមិនអាចសំអាងលើខនេះដើម្បីមិនគោរពសន្ធិសញ្ញាបាននោះឡើយ[27]។

### ៤.៣ ការផុតរលត់នៃខដាក់ល័ក្ខខ័ណ្ឌ

ខដាក់ល័ក្ខខ័ណ្ឌ អាចត្រូវបានសុំដកចេញវិញបាន គ្រប់ពេលវាលាទាំងអស់ជាពិសេស នៅពេលដែលរដ្ឋដែលអ្នកដាក់ខនោះ យល់ឃើញថាខ្លួនគ្មានបានទាញអត្ថប្រយោជន៍ពីទង្វើ របស់ខ្លួនតទៅទៀត។[28]

## កថាខណ្ឌទី៣៖ កិច្ចព្រមព្រៀងទម្រង់សាមញ្ញ

ជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលចូលជាធរមាននៅពេលដែលចុះហត្ថលេខារួច ដោយមិនចាំបាច់ រង់ចាំការផ្តល់សច្ចាប័ននោះទេ។ ឧទាហរណ៍៖ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ស្តីពី ការដំណោះស្រាយជម្លោះនៅកម្ពុជា។

[26] ICJ, Certain Norwegian Loans (France v. Norway), Judgment of 6 July 1957.

[27] ICJ, Military and Paramilitary Activities in and against Nicaragua (Nicaragua v. United States of America), 1984.

[28] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៣៩-៤២។

កិច្ចព្រមព្រៀងប្រភេទនេះ ត្រូវមានធាតុផ្សំដូចគ្នានឹងកិច្ចព្រមព្រៀងអន្តរជាតិទូទៅដែរ គឺត្រូវមានឯកសារសរសេរជាលាយលក្ខណ៍អក្សរ បញ្ជាក់ពីទីកន្លែង និងកាលបរិច្ឆេទ នៃការយល់ព្រមរបស់អ្នកទទួលបាន អំណាចពេញសមត្ថកិច្ច និងមានអានុភាពបង្ខំ ហើយធ្វើឡើងក្នុងក្របខ័ណ្ឌនៃនីតិ អន្តរជាតិ។

គេច្រើនប្រើកិច្ចព្រមព្រៀងប្រភេទនេះក្នុងទំនាក់ទំនងរដ្ឋបាល ឬបច្ចេកទេស ឬយុទ្ធសន្តិភាព(Armistic)។ ឧទាហរណ៍ៈ កិច្ចព្រមព្រៀងរដ្ឋបាលប្រៃសណីយ៍។ ផលប្រយោជន៍ ដែលគេចូលចិត្តធ្វើកិច្ចព្រមព្រៀងប្រភេទនេះគឺដោយសារវាមានភាពងាយស្រួល និងរហ័សទាន់ចិត្ត ក្នុងការធ្វើនីតិវិធីជាធរមាន។

## កថាខណ្ឌទី៤ៈ អនុសញ្ញាខាងអង្គការអន្តរជាតិ

អនុសញ្ញាប្រភេទនេះពុំមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩ ទេ។ ដូច្នេះវាជាបញ្ហាថ្មី និងស្មុគស្មាញពីព្រោះវាគ្មានវិធានជាឯកសណ្ឋានណាមួយ ដែលអាចយកមកប្រើការបាននៅឡើយទេ។ ក៏ប៉ុន្តែបញ្ញត្តិនៃអនុសញ្ញា ជាមូលដ្ឋានទាក់ទងនឹងអង្គការអន្តរជាតិ មានច្រើនសណ្ឋាន។ អត្ថបទខ្លះអនុញ្ញាតអោយអង្គការអន្តរជាតិ ចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នផ្សេងៗទៀត។ ដូចជាករណីមាត្រា៦៣ នៃធម្មនុញ្ញសហប្រជាជាតិអនុញ្ញាតអោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច(ECOSOC) ចុះកិច្ចព្រមព្រៀងជាមួយ ស្ថាប័នជំនាញផ្សេងៗក្រោមការយល់ព្រមពីមហាសន្និបាទនៃអង្គការសហប្រជាជាតិ (UNGA)។

គណៈកម្មការនីតិអន្តរជាតិ បានសម្រេចនូវអនុសញ្ញាទីក្រុងវីយែន មួយទៀតនៅខែមិថុនា ឆ្នាំ១៩៨៦ ដែលបានចែងអំពីអនុសញ្ញាអន្តរជាតិដែលធ្វើឡើងដោយអង្គការអន្តរជាតិ។

ការចុះកិច្ចព្រមព្រៀងប្រភេទនេះមាន បីដំណាក់កាលដូចតទៅៈ

1) ការចរចា
2) ការចុះហត្ថលេខា
3) ការយល់ព្រម

## ផ្នែកទី២ ល័ក្ខខ័ណ្ឌគ្រឹះនៃសន្ធិសញ្ញាអន្តរជាតិ

តាមពិតទៅ សន្ធិសញ្ញាអន្តរជាតិ មិនមានលក្ខណៈខុសគ្នានឹងកិច្ចសន្យាឯកជននោះទេ ដែលវាទាមទារអោយមានបំពេញនូវល័ក្ខខ័ណ្ឌគ្រឹះ ដើម្បីអាចអោយវាបង្កើតនូវអានុភាពគតិយុត្តបាន។ ល័ក្ខខ័ណ្ឌនេះ សំដៅធ្វើការនិយ័តភាព នៃការយល់ព្រមរបស់គូភាគី និងភាពស្របច្បាប់នៃកម្មវត្ថុរបស់ សន្ធិសញ្ញាអន្តរជាតិ។

### កថាខណ្ឌទី១៖ វិការៈនៃការយល់ព្រមរបស់ភាគី

សន្ធិសញ្ញា ដែលត្រូវបានធ្វើឡើងដោយគ្មានអសុពលភាព ដរាបណាភាគីណាមួយរកឃើញនូវវិការៈណាមួយដែលប៉ះពាល់ដល់ការយល់ព្រមរបស់ភាគី។

វិការៈមានបីប្រភេទគឺ ការចាប់បង្ខំ ការភាន់ច្រឡំ និងការបំភាន់ ឬការលួចបន្លំ។

#### ១. ការចាប់បង្ខំ

ការចាប់បង្ខំ ឬការប្រើប្រាស់អំពើហិង្សា គឺជាទង្វើមួយ ដែលនាំអោយមានការរំលាយ កិច្ចព្រម ព្រៀងបាន។ គេអាចធ្វើអំពើទៅលើរដ្ឋ ឬទៅលើតំណាងពេញសមត្ថកិច្ចរបស់រដ្ឋនោះបាន។[29]

#### ១.១ ការចាប់បង្ខំលើរដ្ឋ

មាត្រា៥២ នៃអនុសញ្ញាទីក្រុងវីយែន[30] ចែងថាត្រូវចាត់ទុកជាមោឃៈនូវសន្ធិសញ្ញាទាំងឡាយណា ដែលការយល់ព្រមរបស់វាត្រូវបានធ្វើឡើង ដោយមានការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងពីសំណាក់អ្នកដ៏ទៃ ដែលរំលោភបំពានទៅលើគោលការណ៍នៃនីតិអន្តរជាតិ ដូចមានចែងឡើងដោយធម្មនុញ្ញាសហប្រជាជាតិ។ ពេលនេះឃើញមានថាមានតែការរំលោភ បំពាន ដោយយោធាប៉ុណ្ណោះ ដែលគេចាត់ទុកថាជាអំពើខុសច្បាប់។

សន្ធិសញ្ញា ដែលមានវិសមភាពមួយចំនួន ត្រូវបានសើរើឡើងវិញ។ ឧទាហរណ៍៖ ដូច ជាសន្ធិសញ្ញាវិសមភាព ដែលធ្វើឡើងដោយការចាប់បង្ខំពីសំណាក់មហាអំណាចអឺរ៉ុប នៅក្នុងអាណានិគម និងចក្រពត្តិនិយម។ ករណីវិវាទសូវៀត ត្រូវដោះស្រាយដោយប៉េរះស្ត្រួយការ (Pérestroïka) លក្ខន្តិកៈហុងកុង និងម៉ាក់ការ ត្រូវសើរ

---

[29] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៤៣-៤៥។

[30] មាត្រា៥២៖ ការចាប់បង្ខំទៅលើរដ្ឋតាមរយៈការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ត្រូវចាត់ទុកជាមោឃៈ រាល់សន្ធិសញ្ញាទាំងឡាយណាដែលធ្វើឡើងតាមរយៈការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ដោយការរំលោភបំពានលើគោលការណ៍នៃនីតិអន្តរជាតិ ដែលទទួលស្គាល់ក្នុងធម្មនុញ្ញសហប្រជាជាតិ។

ពីដោយចិន តាមរយៈកិច្ចសន្យាព្រមព្រៀងឆ្នាំ ១៩៨៤ និងឆ្នាំ១៩៨៧ ស្តីពីការប្រគល់ទឹកដីទាំងពីរអោយទៅចិនវិញ ហុងកុង នៅខែកក្កដា ឆ្នាំ១៩៩៧ ម៉ាក់ការ (Macao) នៅខែធ្នូ ឆ្នាំ១៩៩៩ ប៉ុន្តែត្រូវឆ្លងកាត់ដំណាក់កាលអន្តរកាល រយៈពេល៥ឆ្នាំ។

## ១.២ ការចាប់បង្ខំលើតំណាងពេញសមត្ថកិច្ចរបស់រដ្ឋ

ការសម្តែងការយល់ព្រមរបស់រដ្ឋ ចំពោះសន្ធិសញ្ញាណាមួយ ដែលទទួលបានតាមការចាប់បង្ខំទៅលើតំណាងរបស់រដ្ឋនោះ ដូចជាអំពើ ឬការគំរាមកំហែងជាដើម ត្រូវបាត់បង់រាល់អានុភាពគតិយុត្តទាំងអស់[31]។ ឧទាហរណ៍៖ កិច្ចព្រមព្រៀងហាឆា-ហ៊ីត្លែរ (Hacha-Hitler) ត្រូវបានធ្វើឡើងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៣៩ ដើម្បីធ្វើអោយការកាន់កាប់ដោយយោធារបស់អាល្លឺម៉ង់ នៅលើទឹកដីប្រទេសឆេកូស្លូវ៉ាគី ទៅជាស្របច្បាប់ កាលនោះលោក ហ៊ីត្លែរ (Hitler) បានអញ្ជើញលោក អេមីល ហាឆា (Emil Hacha) ប្រធានាធិបតីនៃប្រទេស ឆេកូស្លូវ៉ាគី អោយទៅទស្សកិច្ចនៅទីក្រុងប៊ែកឡាំង (Berlin) ប្រទេសអាឡឺម៉ង់ ហើយលោក ហ៊ីត្លែរ បានបង្ខំអោយលោក អេមីល ហាឆា ចុះកិច្ចព្រមព្រៀងស្តីពី ការទទួលយកអាណាព្យាបាល របស់អាល្លឺម៉ង់[32]។ [33]

ដើម្បីជៀសវាងមោឃភាពនៃសន្ធិសញ្ញា ការផ្តល់សច្ចាប័ន គឺជាមធ្យោបាយដ៏ល្អមួយ ក្នុងការឆ្លើយតបនឹងអំពើដែលគេចាត់ទុកថាខុសច្បាប់នេះ។[34]

## ២. ការភាន់ច្រឡំ

យោងតាមមាត្រា៤៨ នៃអនុសញ្ញាទីក្រុងវីយែន នៅក្នុងនីតិអន្តរជាតិ បញ្ហាភាន់ច្រឡំលើអង្គច្បាប់ មិនត្រូវបានគេទទួលស្គាល់ទេ។ គឺមានតែការភាន់ច្រឡំលើអង្គហេតុប៉ុណ្ណោះ ទើបគេទទួលស្គាល់ថាជាអំពើខុសច្បាប់ ហើយភាគីអាចទាមទារសុំរំលាយសន្ធិសញ្ញាបាន តែវាត្រូវគោរពល័ក្ខខ័ណ្ឌមួយចំនួនដូចតទៅ៖

1) ការភាន់ច្រឡំ ដែលបណ្តាលអោយរដ្ឋ ផ្តល់ការយល់ព្រម ត្រូវតែមានកើតលើហេតុការណ៍ ឬស្ថានភាពណាមួយ ដែលរដ្ឋនោះចាត់ទុកថាមានពិតប្រាដកនៅពេលដែលខ្លួនចុះកិច្ចព្រមព្រៀង ហើយវាជាមូលដ្ឋាននៃ

---

31 Vienna Convention 1969 (អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៥១

32 www.radio.cz/fr/article/30346

33 អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៤៦។

ការយល់ព្រមរបស់ខ្លួនទៀត។ ឧទាហរណ៍៖ សាលដីការរបស់តុលាការ យុត្តិធម៌អន្តរជាតិ ICJ ក្នុងរឿងក្តីប្រាសាទព្រះវិហារ ជម្លោះរវាងថៃ និងកម្ពុជា ឆ្នាំ១៩៦១ តុលាការកាត់ក្តីស្តីពី សមត្ថកិច្ច CIJ, affaire du Temple de Preah-Vihear entre la Thailande & le Cambodge, arrêt sur les exceptions preliminaries, 1961។

2) ការភាន់ច្រឡំត្រូវ គេចាត់ទុកថាមានសភាពធ្ងន់ធ្ងរ។ ឧទាហរណ៍៖ សាលដីការ របស់តុលាការ យុត្តិធម៌អន្តរជាតិ ICJ ក្នុងរឿងក្តី CIJ, affaire des parcelles frontalières entre la Belgiuque et les Pays-Bas, 1961 ។

3) រដ្ឋរងគ្រោះ មិនត្រូវមានឥរិយាបទណាមួយចូលរួមក្នុងការភាន់ច្រឡំនេះទេ ឬត្រូវបាន គេអោយដំណឹងទាន់ពេលវេលាទៅហើយ តែមានការធ្វេសប្រហែល មិនព្រមចាត់វិធានការ។ ឧទាហរណ៍៖ សាលដីការរបស់តុលាការយុត្តិធម៌ ICJ ក្នុងរឿងក្តី CIJ, affaire Temple de Prèah Vihear, arrêt sur le fond du 15 juin 1962។

### ៣.ការបំភាន់ ឬការលួចបន្លំ

ការលួចបន្លំ គឺជាការប្រើល្បិចកលរបស់ភាគីណាមួយ ដើម្បីធ្វើយ៉ាងណាអោយភាគីម្ខាងទៀត ផ្តល់ការយល់ព្រមរបស់ខ្លួន។ មាត្រា៤៩ នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ បានចែងថាការយល់ ព្រមរបស់រដ្ឋភាគីមួយត្រូវបានបន្លំដោយរដ្ឋភាគីម្ខាងទៀត ដែលបានចូលរួមចរចា ពោលគឺរដ្ឋនោះជឿជាក់ថា ពិតនូវអ្វីដែលមិនពិតដោយសារតែមានការលួចបន្លំ ឬការបំភាន់។ រដ្ឋនេះអាចអះអាង បញ្ជាក់ថាមានការលួចបន្លំ ទៅលើការយល់ព្រមរបស់ខ្លួនបានដើម្បីសុំរំលាយ កិច្ចព្រមព្រៀងនោះបាន។

ការលួចបន្លំនេះ ត្រូវតែស្តែងឡើងតាមរយៈឆន្ទៈរបស់រដ្ឋភាគីខូចខិល។ ករណីនៃការបំភាន់បែបនេះ ពុំសូវមានកើតឡើងឡើយ នៅក្នុងការអនុវត្តជាកស្តែង។[35]

[35] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៤៨។

**កថាខណ្ឌទី២៖ ភាពខុសច្បាប់នៃកម្មវត្ថុរបស់សន្ធិសញ្ញា**

មាត្រា៥៣ នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ បញ្ចូលសញ្ញាណនៃបទដ្ឋានអាជ្ញាបញ្ញា ដែលជាអក្សរឡាតាំង Jus Cogens។ បទដ្ឋានអាជ្ញាបញ្ញា គឺជាបទដ្ឋានមួយដែលគ្មានសន្ធិសញ្ញាណាមួយអាច ធ្វើបដិប្បញ្ញត្តិប្រឆាំងនឹងវាបានឡើយ។ តែបើមានការប្រឆាំងនឹងបទដ្ឋាននេះ សន្ធិសញ្ញានោះនឹងត្រូវ បាន គេទុកជាមោឃៈភ្លាម។

យោងតាមមាត្រា៥៣ នេះ វិធានអាជ្ញាបញ្ញានៅក្នុងនីតិអន្តរជាតិទូទៅ គឺជាបទដ្ឋានមួយ ដែលយល់ព្រម និងទទួលស្គាល់ដោយសហគមន៍អន្តររដ្ឋទាំងមូល ថាបទដ្ឋានដែលគេមិនអាចធ្វើបដិប្បញ្ញត្តិបាន ដោយគិតពីសន្ធិសញ្ញា ដែលកំពុងចាប់បដិសន្ធិ។ លើសពីនេះទៅទៀត ប្រសិនបើមាន បទដ្ឋានអាជ្ញាបញ្ញាថ្មី ណាមួយកើតឡើង ហើយមានសន្ធិសញ្ញាណាមួយដែលមានពីមុនមក មានកម្មវត្ថុរបស់ខ្លួនផ្ទុយនឹង បទដ្ឋានអាជ្ញាបញ្ញាកើតថ្មីនោះ សន្ធិសញ្ញានឹងត្រូវចាត់ទុកជាមោឃៈ ហើយវាត្រូវតែ បញ្ចប់រាល់អានុភាពគតិយុត្ត ទាំងអស់ភ្លាម[36]។ ឧទាហរណ៍៖ គ្មានសន្ធិសញ្ញាណាមួយ ត្រូវបានគេទទួលស្គាល់ទេ ប្រសិនបើវាធ្វើឡើង ដោយប្រឆាំងនឹងវិធាន ដែលគេចាត់ទុកជាវិធានអាជ្ញាបញ្ញា ដូចជា៖ វិធានដែលទាក់ទងទៅនឹង ការហាមមិនអោយបង្ករ និងប្រព្រឹត្តអំពីឧក្រិដ្ឋកម្ម អំពើឈ្លានពាន អំពើទាសភាព អំពើទារុណកម្មឃោឃៅព្រៃផ្សៃ អមនុស្សធម៌ ។ល។ អាចនិយាយម្យ៉ាងទៀតបានថា សន្ធិសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយណា ដែលបំពារបំពានលើបម្រាមពិភពលោក នឹងត្រូវបំផ្លាញចោល។

មាត្រា៥៣ ដដែលបន្ថែមថា គឺមានតែបទដ្ឋានអាជ្ញាបញ្ញាថ្មីប៉ុណ្ណោះ ដែលអាចធ្វើវិសោធនកម្មលើ បទដ្ឋានអាជ្ញាបញ្ញា ដែលមានពីមុនមក។

ក្នុងករណីមានកើតវិវាទ ទាក់ទងនឹងការអនុវត្តនៅក្នុងមាត្រា៥៣ និងមាត្រា៦៤ ខាងលើនោះគឺ តុលាការយុត្តិធម៌អន្តរជាតិ ICJ ជាអ្នកមានសមត្ថកិច្ច[37]។

**កថាខណ្ឌទី៣៖ អានុភាពនៃមោឃភាពនៃសន្ធិសញ្ញា**

មាត្រា៦៩ នៃអនុសញ្ញាទីក្រុងវីយែនចែងថាបញ្ញត្តិនៃសន្ធិសញ្ញា ដែលគេទុកជាមោឃៈ គ្មានអានុភាពគតិយុត្តឡើយ ពោលគឺមោឃៈភាពរបស់វា គិតចាប់តាំងពីថ្ងៃកើតនៃសន្ធិសញ្ញា តែមិនមែនគិតពីពេល ដែលមានការវាយតម្លៃលើមោឃភាពនោះទេ។ មោឃភាពនៃសន្ធិសញ្ញា អាចជាដាច់ខាត ឬមិនដាច់ខាត គឺថា ករណីទី១សន្ធិសញ្ញាត្រូវបានគេប្រកាសមោឃភាពទាំងមូលតែម្តង។ ចំណែកទី២ មានខមួយចំនួននៅ ក្នុងសន្ធិសញ្ញាប៉ុណ្ណោះ

[36] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦៤

[37] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦៦។

ដែលត្រូវគេទុកជាមោឃៈ ហើយខទាំងនោះអាចផ្តាច់ខ្លួនចេញពីសន្ធិសញ្ញា ដោយពុំប៉ះពាល់ដល់សន្ធិសញ្ញាទាំងមូលឡើយ។[38]

## ជំពូកទី៣
## ការប្រតិបត្តិ សន្ធិសញ្ញាអន្តរជាតិ

ក្រោយកិច្ចចុះកិច្ចព្រមព្រៀងរួចហើយ យើងនឹងងាយមកធ្វើការសិក្សាអំពីនីតិវិធី ក្នុងការយកខ្លឹមសារអត្ថបទសន្ធិសញ្ញាមកអនុវត្ត ដោយផងដែរទាមទារការគោរពទៅតាម គោលការណ៍អន្តរជាតិចម្បងនានាដូចជាៈ

បើយោងតាមគោលការណ៍ "Pacta Sunt Servanda[39]" គ្រប់សន្ធិសញ្ញាដែលចូលជាធរមាន មានកម្លាំងបង្ខំទៅលើភាគីទាំងអស់នៃសន្ធិសញ្ញា ហើយភាគីទាំងអស់នៃសន្ធិសញ្ញាត្រូវអនុវត្តដោយសុទ្ធចិត្ត[40]។

ភាគីមិនអាចលើកឡើងអំពីបទបញ្ញត្តិ នៃនីតិក្នុងស្រុករបស់ខ្លួន ក្នុងការដោះសារពីការមិនអនុវត្តសន្ធិសញ្ញា[41]។

ដូចនេះយើងអាចនិយាយបានថា គ្រប់សន្ធិសញ្ញាទាំងឡាយណាដែលចូលជាធរមានហើយ គ្រប់ភាគីដែលជាភាគីហត្ថលេខី (ប្រធាននៃនីតិអន្តរជាតិសារធារណៈ រដ្ឋ និងអង្គការអន្តរជាតិ) ត្រូវតែប្រតិបត្តិតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិ ដែលខ្លួនបានចុះហត្ថលេខា ដោយសុទ្ធចិត្តភាព និងភាព ស្មោះត្រង់ ដោយមិនបំពារបំពាន ឬជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងគ្នា ព្រមទាំងគោរពនូវអធិបតេយ្យភាពរបស់រដ្ឋជា សមា

[38] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៥០។

[39] "Pacta sunt Servanda described as a significant general principle of international law, Pacta Sunt Servanda lies at the root of every agreement, as an obligation that al treaties freely concluded, and in force between State and other subjects of international law, are to be implemented. This is to be done in good faith. More, States are under the obligation not to defeat the object of a treaty even prior to its entry into force. This principle is concomitant with the growing elaboration of international law, the forging of greater ties of community between States and ensuring a greater reliability of the treaty nexus between one State and another." Encyclopaedia of Public of International Law, Instalment 7, 1984.

[40] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា២៦។

[41] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា២៧។

ជិក គោរពនូវដែនដី និងរួមទាំងអំណាចផ្តាច់មុខរបស់រដ្ឋ ដែលមិនអាចរំលោភបំពានបានដាច់ខាត មិនអាចដកហូត និងនៅជាអចិន្ត្រៃយ៍ជានិច្ច ជាពិសេសទៅទៀត គឺជាចំណងកាព្វកិច្ច នៅក្នុងសហគមន៍ អន្តរជាតិ។

ចំណែកគោលការណ៍ Jus Cogens (Peremptory Norm)[42] ត្រូវបានចាត់ទុកជាវិធានកំពូលក្នុងនីតិអន្តរជាតិសារធារណៈ ដែលជាសត្យានុម័ត សន្ធិសញ្ញាមួយត្រូវទុកជាមោឃៈ ប្រសិនបើនៅពេលដែលចុះហត្ថលេខាលើសន្ធិសញ្ញានោះ សន្ធិសញ្ញានោះមានការប៉ះទង្គិចជាមួយនឹងបទដ្ឋាន ទូទៅដែលមានសារៈសំខាន់បំផុត នៃនីតិអន្តរជាតិ។ យោងទៅតាមអនុសញ្ញានេះ បទដ្ឋានទូទៅមានសារៈសំខាន់បំផុតនៃនីតិអន្តរជាតិ គឺជាបទដ្ឋានដែលព្រមទទួល និងត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិ នៃរដ្ឋ ទាំងមូលថាជាបទដ្ឋាន ដែលមិនអនុញ្ញាតអោយមានបដិប្បញ្ញត្តិ និងជាបទដ្ឋានដែលអាចធ្វើការកែប្រែបាន ដរាបណាបទដ្ឋាននៃនីតិអន្តរជាតិក្រោយមានលក្ខណៈដូចគ្នា។[43]

រីឯគោលការណ៍ Clausula Rebus Sic ជាគោលការណ៍មួយ ដែលមានទំនាក់ទំនង់ជាមួយគោលការណ៍ ទាំងពីរខាងលើ ពោលអាចរដ្ឋសុំអនុវត្ត តែដោយសម្រួល និងបន្ធូរបន្ថយដល់ភាគីទាំងអស់នៃសន្ធិសញ្ញាចំពោះ ការលំបាកនៃការប្រតិបត្តិសន្ធិសញ្ញា។ បើទោះបីកិច្ចព្រមព្រៀងអន្តរជាតិ មានសណ្ឋានស្រដៀងនឹងកិច្ចសន្យាឯកជន ហើយត្រូវបានចាត់ទុកថាជាច្បាប់របស់គូភាគី[44] ដែលទាមទារអោយមានការអនុវត្តស្របទៅតាមច្បាប់ដែលខ្លួនចែង យ៉ាងណាមិញគោលការណ៍នេះបានដើរតួនាទីជាអ្នកសម្របសម្រួលអោយរដ្ឋភាគីដែលជួបការ លំបាក អាចអនុវត្តបានក្នុងល្បឿន និងក្របខ័ណ្ឌដែលខ្លួនធ្វើទៅរួច។

## ផ្នែកទី១៖ នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញាអន្តរជាតិ

ដងខ្លួននៃសន្ធិសញ្ញាតែងចែងនូវល័ក្ខខ័ណ្ឌ មាត្រា ដែលជាកម្មវត្ថុដែលភាគីចង់បាន ហើយនៅក្នុងនោះផងដែរការអនុវត្តអាចនឹងប៉ះទង្គិច នឹងសកម្មភាព ឬព្រឹត្តិការណ៍ ដែលបានកើតឡើងរួចទៅហើយ

[42] Jus Cogen is a peremptory norm of general international law. Jus Cogen is a norm accepted by the international community of States as a whole can modified only by a subsequent form of general international law having the same character… The words "as a whole" indicate that acceptance in not require by each and every member of the international community… there is a close connection between jus Cogen and the recognition of a public order of the international community" LACHS, MANFRED, "jus cogens (169)" in: Collected Courses of the Hague Academy of International Law, 1980.

[43] Vienna Convention on the Law of Treaties in 1969 (អនុសញ្ញាទីក្រុងវៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា ឆ្នាំ១៩៦៩), បកប្រែក្រៅផ្លូវការ អ៊ីវ ប៉ូលី, មាត្រា ៥៤។

[44] ក្រឹត្យច្បាប់លេខ៣៨, មាត្រា ២២។

ប្រសិនបើសន្ធិសញ្ញានោះ បានបញ្ញត្តិអំពីភាពប្រតិសកម្ម។ "ភាពមិនប្រតិសកម្មនៃសន្ធិសញ្ញា លុះត្រាតែមានឆន្ទៈផ្សេងកំណត់ក្នុងសន្ធិសញ្ញា ឬមានការបញ្ញត្តិច្បាស់លាស់ បទបញ្ញត្តិរបស់សន្ធិសញ្ញា មិនមានកំលាំងចាប់បង្ខំអោយភាគីគោរពតាមចំពោះសកម្មភាព ឬអង្គហេតុទាំងឡាយណាដែលបានកើតឡើង ឬចំពោះស្ថានភាពទាំងឡាយណា ដែលបានបញ្ចប់រួចហើយ មុនកាលបរិច្ឆេទ នៃការចូលជាធរមាន នៃសន្ធិសញ្ញា"[45]។

បើយោងតាមខ្លឹមសារនៃមាត្រាខាងលើនេះ យើងអាចគូរបញ្ជាក់បានថាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិណាក៏ដោយ មិនមាននោះទេនូវតម្លៃគតិយុត្តិ ក្នុងការអនុវត្តថយក្រោយ ពោលគឺគ្រប់សកម្មភាពណាដែលពាក់ព័ន្ធ ឬព្រឹត្តិការណ៍ទាំងឡាយណា ដែលបានកើតឡើង និងបានបញ្ចប់ទៅរួចទៅហើយមុនកាលបរិច្ឆេទចូលជាធរមាន នៃសន្ធិសញ្ញា។ ទាល់តែមានការបញ្ញាត្តិយ៉ាងច្បាស់លាស់ក្នុងសន្ធិសញ្ញា (ថាកិច្ចព្រមព្រៀងនេះមានភាពប្រតិសកម្ម) ពីគូរភាគី ទើបអាចអនុវត្តថយក្រោយបាន។

សន្ធិសញ្ញា ជាទូទៅត្រូវធ្វើការចែងអំពីបទបញ្ញត្តិ ស្តីពីដែនវិសាលភាពក្នុងការអនុវត្ត ដោយបញ្ជាក់អំពីទំហំនៃអានុភាពរបស់សន្ធិសញ្ញា ដោយក្នុងនោះច្បាប់ស្តីពីសន្ធិសញ្ញាក៏បានបញ្ជាក់អំពីចំណុចផងដែរដែលមានដូចតទៅ "អានុភាពតាមដែនដីរបស់សន្ធិសញ្ញា លុះត្រាតែមានឆន្ទៈផ្សេងកំណត់ក្នុងសន្ធិសញ្ញា ឬមានការបញ្ញត្តិច្បាស់លាស់ សន្ធិសញ្ញាមួយមានកំលាំងចាប់បង្ខំអោយភាគីនីមួយៗ គោរពតាមនៅលើដែនដីទាំងមូលរបស់រដ្ឋ"[46]។

ជាគោលការណ៍ អានុភាពគតិយុត្តិនៃសន្ធិសញ្ញា មានអានុភាពអនុវត្តលាតសន្ធឹងគ្របដណ្តប់លើដែនបូរណភាពទឹកទាំងមូល របស់រដ្ឋជាគូភាគីតែម្តង។ តែក៏អាចមានល័ក្ខខ័ណ្ឌផ្សេងពីនេះផងដែរ ដែលកិច្ចព្រមព្រៀងនោះ អាចអនុវត្តបានតែលើនៅចំណុចដែលកិច្ចព្រមព្រៀងបានអនុញ្ញាតប៉ុណ្ណោះ។ ឧទាហរណ៍ៈ កិច្ចព្រមព្រៀងជួលកំពង់ផែ ទៅអោយរដ្ឋណាមួយ។

នៅក្នុងទំនាក់ទំនងដ៏សែនប្រទាក់ក្រឡាវាងប្រធាន នៃនីតិអន្តរជាតិ មានសន្ធិសញ្ញាមិនតិចនោះទេដែលមានកម្មវត្ថុដូចគ្នា ហើយក៏មានមិនតិចដែរនូវសន្ធិសញ្ញាចាស់ ត្រូវជំនួសដោយសន្ធិសញ្ញាថ្មី ដែលមាន

[45] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា២៨។

[46] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា២៩។

រក្សាទុកនូវកម្មវត្ថុចាស់ ហើយ (ដើម្បីអោយកាន់តែល្អប្រសើរ) បន្ថែមនូវកម្មវត្ថុថ្មី ក្នុងនោះយើងក៏មានមាត្រា ដែលពាក់ព័ន្ធក្នុងការ គ្រប់គ្រងបាតុភូតប្រភេទនេះ។

ការអនុវត្តបន្តនូវសន្ធិសញ្ញាដែលមានកម្មវត្ថុដូចគ្នា ធម្មនុញ្ញអង្គការសហប្រជាជាតិ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងអស់នៅក្នុងការអនុវត្តបន្តនូវសន្ធិសញ្ញា ដែលមានកម្មវត្ថុដូចគ្នា និងត្រូវកំណត់នៅក្នុងកថាខណ្ឌដូច ខាងក្រោម[47]៖

1) ប្រសិនបើសន្ធិសញ្ញាចែងថា សន្ធិសញ្ញាយោងទៅលើ (ឬសន្ធិសញ្ញានេះមិនត្រូវបានចាត់ទុកថាផ្ទុយជាមួយ) សន្ធិសញ្ញាចាស់ ឬថ្មី នោះសន្ធិសញ្ញាដែលបានចែងបទបញ្ញត្តិដូចនេះមានឧត្តមភាព។

2) ប្រសិនបើភាគីទាំងអស់នៃសន្ធិសញ្ញាថ្មី ក៏ជាភាគីនៃសន្ធិសញ្ញាចាស់ដែលនោះ ប៉ុន្តែសន្ធិសញ្ញាចាស់មិនបានលុបចោល ឬពន្យាការអនុវត្តដូចមានចែងក្នុងមាត្រា៥៩ នោះសន្ធិសញ្ញាចាស់អនុវត្តតែបទបញ្ញត្តិទាំងឡាយ ដែលមានភាពសមស្របជាមួយបទបញ្ញត្តិនៃសន្ធិសញ្ញាថ្មីប៉ុណ្ណោះ។

3) ប្រសិនបើភាគី នៃសន្ធិសញ្ញាថ្មី មិនបានរួមបញ្ចូលភាគីទាំងអស់នៃសន្ធិសញ្ញាមុននោះទេ៖

ក.ចំពោះរដ្ឋទាំងឡាយដែលជាភាគី នៃសន្ធិសញ្ញាទាំងពីរ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិដែលមាននៅក្នុងកថាខណ្ឌ៣។

ខ.ចំពោះរដ្ឋដែលជាភាគី នៃសន្ធិសញ្ញាទាំងពីរ និងរដ្ឋដែលជាភាគីតែមួយ នៃសន្ធិសញ្ញានោះ សន្ធិសញ្ញា ដែលមានភាគីទាំងពីរជាសមាជិក គ្របគ្រង់ទៅលើសិទ្ធិ និងកាតព្វកិច្ចរវាងរដ្ឋទាំងពីរ។

4) កថាខណ្ឌ៤ មិនប៉ះពាល់ដល់មាត្រា៤១ (កិច្ចព្រមព្រៀងដើម្បីធ្វើការកែប្រែសន្ធិសញ្ញាពហុភាគី រវាង ភាគីមួយចំនួននៃសន្ធិសញ្ញា) ឬមានបញ្ហាចំពោះការទទួលខុសត្រូវ ដែលអាចត្រូវលើកឡើងដោយរដ្ឋនៅ ពេលចុះហត្ថលេខា ឬការអនុវត្តសន្ធិសញ្ញា ចំពោះបទបញ្ញត្តិដែលផ្ទុយជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋចំពោះរដ្ឋផ្សេងទៀត ដែលមានចែងក្នុងសន្ធិសញ្ញាផ្សេងទៀត។

[47] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៣០។

## ផ្នែកទី២៖ អនុភាពសន្ធិសញ្ញាចំពោះតតិយរដ្ឋ

អនុសញ្ញាទីក្រុងវីយែន បានចែងថាសន្ធិសញ្ញាមិនបង្កើតនូវកាតព្វកិច្ច ឬសិទ្ធិលើតតិយរដ្ឋ ដោយមិនមានការយល់ព្រមពីតតិយរដ្ឋនោះទេ។ គោលការណ៍នេះ ត្រូវបានទទួលស្គាល់ ដោយយុត្តិសាស្ត្រអន្តរជាតិ។[48]

ប៉ុន្តែគោលការណ៍នេះ ទទួលនឹងលើកលែង ប្រសិនបើរដ្ឋជាភាគីនៃសន្ធិសញ្ញា មានគោលបំណងអោយបទបញ្ញត្តិនោះ ផ្តល់ឱ្យនូវសិទ្ធិនោះចំពោះតតិយរដ្ឋ ឬចំពោះរដ្ឋមួយក្រុមជាសមាជិកនៃរដ្ឋសហព័ន្ធ ឬរដ្ឋសហព័ន្ធទាំងមូល ហើយតតិយរដ្ឋនោះត្រូវយល់ព្រមទទួលនូវសិទ្ធិនោះដែរ។[49]

ក្នុងករណីរដ្ឋ ដែលជាតតិយភាគី ផ្តល់នូវការយល់ព្រមរបស់ខ្លួន សន្ធិសញ្ញាអាចបង្កឱ្យមាននូវកាតព្វកិច្ច និងសិទ្ធិចំពោះរដ្ឋនេះបាន។ ករណីទាំងពីរនេះមានស្ថានភាពខុសគ្នាបន្តិច ព្រោះថាសិទ្ធិអាចត្រូវតតិយភាគីលើក ឡើង ដោយជូនកាលពុំចាំបាច់សំដែងការយល់ព្រមរបស់ខ្លួនចំពោះសន្ធិសញ្ញាពាក់ព័ន្ធទេ។ តែផ្ទុយទៅវិញបើជា កាតព្វកិច្ច ដែលកើតពីសន្ធិសញ្ញានោះវិញដាច់ខាតតតិយភាគីត្រូវ តែសំដែងជាលាយលក្ខណ៍អក្សរ ទើបកាតព្វកិច្ចនេះ អាចមានអានុភាពចំពោះអ្នកនេះបាន។[50]

សន្ធិសញ្ញាសត្យានុម័តខ្លះៗអាចបង្ខំទៅលើរដ្ឋ ដែលមិនមែនជាភាគី ដោយពុំចាំបាច់ការយល់ព្រមរបស់រដ្ឋទាំងនោះឡើយ។ ឧទាហរណ៍៖ ករណីសន្ធិសញ្ញា ដែលបង្កើតនូវលក្ខន្តិកៈដែនដីរបស់រដ្ឋណាមួយ សន្ធិសញ្ញា ដែលបង្កើតលក្ខន្តិកៈផ្លូវគមនាគមន៍អន្តរជាតិ ឬសន្ធិសញ្ញាដែលបង្កើតអង្គការអន្តរជាតិណាមួយ ឬសន្ធិសញ្ញា ដែលចែងអំពីលក្ខន្តិកៈនយោបាយ(អព្យាក្រឹតភាព សន្ធិសញ្ញា១៨១៥ ការលុបបំបាត់កំលាំងយោធានៅប្រជុំ កោះអាល់ឡែន (Aaland) )។[51]

## ផ្នែកទី៣៖ ការបកស្រាយសន្ធិសញ្ញាអន្តរជាតិពេលជួបខ្លឹមសារនៃសន្ធិសញ្ញានេះ

កិច្ចចងក្រង និងរៀបរៀងជាសន្ធិសញ្ញាអន្តរជាតិត្រូវឆ្លងកាត់ដំណាក់កាលយ៉ាងច្រើន ដែលដំណាក់ កាលនីមួយៗ សុទ្ធសឹងតែមានពេលវាលាយូរ។ យើងអាចរាប់ដោយសង្ខេបដោយចាប់តាំងពីការចរចា ការព្រៀង

[48] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៣៤។

[49] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៣៦។

[50] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៥៦។

[51] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៥៧។

អត្ថបទ ការកែសម្រួល និងការអនុម័ត តែពេលត្រូវអនុវត្តភាគីហត្ថលេខីយ៉ាងច្រើន បានជួបប្រទះ បញ្ហាទាក់ទិននឹងអត្ថន័យ នៃបទបញ្ញត្តិទៅវិញដែលនេះជាបញ្ហាគតិយុត្ត ដែលទាមទារអោយមាននីតិវិធីក្នុងការដោះស្រាយ មួយល្អ។

សន្ធិសញ្ញា នឹងត្រូវបានបកស្រាយដោយសុទ្ធចិត្ត ដោយយោងទៅតាមអត្ថន័យធម្មតា ដែលត្រូវផ្តល់អោយទៅពាក្យពេចន៍នៃសន្ធិសញ្ញានៅក្នុងអត្ថបទ និងដើម្បីបំភ្លឺដល់កម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញា។

អត្ថបទដែលប្រើសម្រាប់បកស្រាយសន្ធិសញ្ញា នឹងត្រូវរួមបញ្ចូលផងដែរបន្ថែមលើអត្ថបទបុព្វកថា និងឧបសម្ព័ន្ធ របស់សន្ធិសញ្ញា[52]។ ចំពោះកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងសន្ធិសញ្ញា ត្រូវបានបង្កើតឡើងរវាងភាគីទាំងអស់ដោយជាប់ទាក់ទងជាមួយនឹង ការចុះហត្ថលេខាទៅលើសន្ធិសញ្ញា។

រដ្ឋជាភាគីអាចធ្វើការបកស្រាយ សន្ធិសញ្ញាដោយចំហពោះ ម្យ៉ាងមានខបកស្រាយនៅក្នុងសន្ធិសញ្ញា ឬម្យ៉ាងទៀតតាមការព្រមព្រៀងគ្នាតាមក្រោយ បន្ទាប់ពីបានចុះសន្ធិសញ្ញា ឬរដ្ឋភាគីអាចធ្វើការបកស្រាយ ដោយស្វាត់ៗ។ ក្នុងករណីមានទំនាស់លើការបកស្រាយនេះ រដ្ឋអាចរត់រកតុលាការមជ្ឈត្តវិនិច្ឆ័យ ឬតុលាការ យុត្តិធម៌អន្តរជាតិ[53]។

ជាបឋម យើងត្រូវយកអត្ថបទមកបកស្រាយតែឯងសិន ដើម្បីរកន័យពិតប្រាកដរបស់វា។ ប្រសិនបើមិនទាន់ត្រឹមត្រូវទៀត គេត្រូវរត់រកបរិបទរបស់កិច្ចព្រមព្រៀងដូចជា តួកិច្ចព្រមព្រៀងទាំងមូល បុព្វកថា និងឧបសម្ព័ន្ធព្រមទាំងគិតគូរដល់កិច្ចព្រមព្រៀងក្រោយៗ មកទៀត និងការអនុវត្តរបស់ភាគីទាំងអស់។ ប្រសិនបើការខិតខំស្វែងរកការបកស្រាយ ប៉ុនហ្នឹងហើយនៅតែពុំមានការយល់ព្រមគ្នាទៀតគេអាចរត់រកកិច្ច ការរៀបរៀងកិច្ចព្រមព្រៀងបន្ថែមទៀត កាលៈទេសៈ នៃការចុះកិច្ចព្រមព្រៀង ឬការអនុវត្តរួចហើយកន្លងមក នៃសន្ធិសញ្ញា[54]។

### កថាខណ្ឌទី១៖ គោលបំណងនៃអ្នកបង្កើត

ការបកស្រាយច្បាប់គឺ គ្មានអ្វីខុសពីការបកស្រាយសន្ធិសញ្ញាប៉ុន្មាននោះទេ ព្រោះការបកស្រាយច្បាប់ គឺជាការបកស្រាយទៅតាមគោលបំណងអ្នកបង្កើតច្បាប់ ជាពិសេសរដ្ឋសភា មានតួនាទីយ៉ាងសំខាន់នៅក្នុង ការជជែកវែកញែក និងពិភាក្សាអំពីគោលបំណង ចរិតលក្ខណៈនៃគោលបំណងបង្កើតមកថាតើគេចង់អ្វី បើដូច្នេះត្រូវតែបក

[52]Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៣១។

[53] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៥៩។

[54] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៦០។

ស្រាយទៅតាមអ្នកធ្វើសេចក្តីព្រាងច្បាប់។ ជាឧទាហរណ៍៖ នៅព្រះរាជាណាចក្រកម្ពុជា រដ្ឋសភាជាតិ មានសិទ្ធិក្នុងកោះអញ្ជើញរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងការអោយមកបកស្រាយ និងសួរដេញដោល នៅពេលដែលខ្លួនបានដាក់ស្នើទៅរាជរដ្ឋាភិបាល ដើម្បីសុំអោយមកបំភ្លឺអំពីទិដ្ឋភាពផ្លូវច្បាប់។ ហើយក្រោយ ពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើដោយ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ១/៤ តំណាងរាស្ត្រ១/១០ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យអំពីធម្មនុញ្ញភាព នៃច្បាប់នោះបាន។[55]

ពីព្រោះក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នមួយដែលមានតួនាទីក្នុងការបកស្រាយ ច្បាប់ ដូច្នេះប្រសិនមានការស្នើសុំអោយមានការបកស្រាយរដ្ឋធម្មនុញ្ញ គឺត្រូវតែបកស្រាយ ហើយគឺត្រូវបកស្រាយទៅតាមគោលបំណង នៃខ្លឹមសាររដ្ឋធម្មនុញ្ញ។[56]

ប៉ុន្តែការបកស្រាយបែបនេះហាក់មានភាពលំអៀង និងមិនមានសុក្រឹត្យ ប្រសិនមានក្រុមមនុស្សដែលមានអំណាចមកលើស្ថានប័ន ឬក៏មានប្រធាន ឬអនុប្រធាន និងសមាជិក ជាអតីតភាពជាសមាជិកនៃ គណបក្សដែលមានឥទ្ធិពល។

**កថាខណ្ឌទី២៖ ការបកស្រាយទូលាយ**

ការបកស្រាយទូលាយ គឺជាវិធីសាស្ត្រមួយ ដែលអ្នកបកស្រាយអាចបត់បែនទៅតាមកាលៈទេស ដែលតម្រូវនៃការចង់បានរបស់អ្នកបកស្រាយ ឬអាចគំនាបពីអ្នកដែលមានឥទ្ធិពលមកលើខ្លួន។ ខ្ញុំគិតថា ការបកស្រាយបែបនេះ អាចមានភាពមិនច្បាស់ដល់អ្នកដែលមានបំណង់ចង់ដឹងអំពីអត្ថន័យនៃខ្លឹមសារសន្ធិសញ្ញា ដូច្នេះមុននឹងធ្វើការបកស្រាយសន្ធិសញ្ញា យើងត្រូវកំណត់នូវនិយមន័យសន្ធិសញ្ញាមួយជាក់លាក់ ដោយលើកជាសំនួរមកថាវាជាសន្ធិសញ្ញាដែលរដ្ឋនិងរដ្ឋ ឬអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ឬជាសន្ធិសញ្ញាប្រភេទបែបណា។ ការបកស្រាយបែបនេះ មានភាពបត់បែនទៅតាមស្ថានភាពសង្គម ដែលអ្នក ដឹកនាំរដ្ឋចង់បាន។[57]

---

[55] ឥន យឿន, មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់ (សាកលវិទ្យាល័យជាតិគ្រប់គ្រង, International Standard Books, ១៩៩៦), ទំព័រ១៧១

[56] It is the exegetic method which makes use of legislative history, see Claire M. Germain, Approaches to Statutory Interpretation and Legislative History in France (Claire, Approaches), 13 Duke Journal of Comparative and International Law, 197 (2003).

[57] មាស បូរ៉ា, នីតិអន្តរជាតិសារធារណៈ (សកលវិទ្យាល័យឯកទេសកម្ពុជា, ២០១៣), ទំព័រ៦៧-៧២។

### ១.១ អត្ថន័យ ឬនិយមន័យ

មុននឹងធ្វើការបកស្រាយសន្ធិសញ្ញា អ្នកបកស្រាយត្រូវកំណត់និយមន័យនៃសន្ធិសញ្ញា និងពាក្យ គន្លឹះឱ្យបានក្បោះក្បាយជាមុន ទើបអាចងាយស្រួលបកស្រាយ ហើយការបកស្រាយត្រូវកំណត់ នូវពាក្យពេចន៍។ ពាក្យ "ត្រូវតែ" មានន័យជាកាតព្វកិច្ច ដែលត្រូវធ្វើតាមចំណែកឯពាក្យ "គួរតែ គ្រាន់តែ" បង្ហាញអំពីអនុសាសន៍ ដែលមិនចងជាកាតព្វកិច្ច។ ពាក្យ "ដូចជា" មានន័យជាពាក្យបង្ហាញជា ឧទាហរណ៍ នូវអ្វីដែលនៅមានជាច្រើនទៀតដែលអ្នកធ្វើច្បាប់គិតថាមិនចាំបាច់សរសេរបញ្ចូលទាំង អស់ក្នុងមាត្រាច្បាប់ នៃខ្លឹមសារសន្ធិសញ្ញា។

ទន្ទឹមនឹងនេះ ការបកស្រាយន័យនៃពាក្យ ត្រូវពិចារណាថ្លឹងថ្លែងផងដែរ នូវខ្លឹមសារនៃមាត្រាក្នុងច្បាប់ ដែលមានបញ្ហា ឬច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត ។ មាត្រា១ នៃកតិកាសញ្ញា ស្ដីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ទាមទារឲ្យរដ្ឋជាភាគី គោរព និងធានាឲ្យបានប្រាកដប្រជា នូវសិទ្ធិរបស់បុគ្គល ស្ថិតនៅក្នុងដែនដី និងស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន។ ផ្ទុយទៅវិញ គណៈកម្មាធិការសិទ្ធិមនុស្ស បានបកស្រាយដោយមើលរំលងនូវអត្ថន័យធម្មតា ដោយផ្ដោតជាសំខាន់លើគោលបំណង នៃសិន្ធិសញ្ញា និងចរិត លក្ខណៈប្រែប្រួល នៃសិទ្ធិមនុស្ស ដែលតាមរយៈនេះបង្កើតនូវកាតព្វកិច្ច គោរពសិទ្ធិសេរីភាពដល់រដ្ឋ ចំពោះទង្វើរបស់ដោយអាជ្ញាធររបស់រដ្ឋ សូម្បីអំពើដែលពាក់ព័ន្ធកើតមាននៅក្រៅដែនដី។

### ១.២ ស្ថានភាពសង្គម

ការបកស្រាយសន្ធិសញ្ញាទៅតាមស្ថានភាពសង្គម គឺតម្រូវឱ្យអ្នកបកស្រាយសន្ធិសញ្ញា របស់ប្រទេសនៃរដ្ឋសមាជិកមួយ ពិនិត្យ អង្កេត និងតាមដានអំពីទិដ្ឋភាពសង្គមបរិបទនៃប្រទេសរបស់ខ្លួន ហើយធ្វើការ បកស្រាយនៃខ្លឹមសារ ក៏ដូចជាគោលបំណងរបស់សន្ធិសញ្ញា ឱ្យស្របទៅតាមបរិបទនៃប្រទេស នៅពេល ដែលពលរដ្ឋនោះបានរិះគន់មកលើរដ្ឋាភិបាល អំពីភាពមិនអនុវត្តចំពោះសន្ធិសញ្ញាអន្តរជាតិ អាចជាការ រិះគន់អំពីការអនុវត្តច្បាប់ ដោយមិនគោរពនូវសិទ្ធិសេរីភាពរបស់រដ្ឋ រំលោភសិទ្ធិមនុស្សជាដើម ប៉ុន្តែជា ឧទាហរណ៍៖ គោលបំណងនៃសន្ធិសញ្ញា ពាក់ព័ន្ធជាមួយសិទ្ធិមនុស្ស គឺដើម្បីការពារផលប្រយោជន៍ របស់បុគ្គល ហេតុដូចនេះ ការបកស្រាយត្រូវតែបកស្រាយយ៉ាងណា ផ្ដល់ន័យដល់ការការពារផលប្រយោជន៍ជាក់ស្ដែង តែបើតាមស្ថានភាព

សង្គម គេអាចធ្វើការបកស្រាយដោយផ្អែកលើស្ថានភាព នៃការការពារផលប្រយោជន៍សាធារណៈ ច្រើនជាងសិទ្ធិបុគ្គល ពីព្រោះសិទ្ធិបុគ្គលត្រូវបានកំណត់ ដោយច្បាប់ទៅតាមស្ថានភាពនៃសង្គមប្រជាជាតិផ្សេងៗគ្នា។[58]

### ១.៣ ការប្រៀបធៀប និងការអនុវត្ត

ការប្រៀបធៀប មានសារៈសំខាន់សម្រាប់ការអនុវត្តចំពោះប្រទេស ឬរដ្ឋដែលជាប្រទេសហត្ថលេខី ដែលចុះសន្ធិសញ្ញាជាមួយគ្នា ជាពិសេសដោយគោរពនូវគោលការណ៍ និងសិទ្ធិសេរីភាពជាសកលរបស់ សេចក្តីថ្លែការជាសកលស្តីពីសិទ្ធិមនុស្ស។

នៅក្នុងសេចក្តីសម្រេចលើរឿងក្តីបត្យាប័ន ស្នើដោយសហរដ្ឋអាមេរិក ចំពោះប្រទេសកាណាដា តុលាការកំពូលរបស់កាណាដា បានពិចារណាយ៉ាងស៊ីជម្រៅ ពាក់ព័ន្ធជាមួយនឹងច្បាប់សន្ធិសញ្ញា សាលក្រម របស់តុលាការអន្តរជាតិ និងរបស់ជាតិ និងឯកសារផ្សេងៗទៀត ដែលជាប់ទាក់ទិនជាមួយការ ហាមឃាត់ទោសប្រហារជីវិត។ តុលាការកំពូលរបស់កាណាដា បានរកឃើញនូវនិន្នាការទូទៅ នៃការលុបចោល ឬការមិនប្រើទោសប្រហារជីវិត។

ផ្អែកតាមរកឃើញនេះ តុលាការ បានតម្រូវឲ្យរដ្ឋាភិបាលកាណាដា សុំការធានាពីសហរដ្ឋអាមេរិក មិនឲ្យប្រើទោសប្រហារជីវិតលើជន ដែលកាណាដា បញ្ជូនទៅវិញ នៅក្នុងគ្រប់ករណីបត្យាប័ន ពាក់ព័ន្ធនឹងទោសប្រហារជីវិត លើកលែងករណីពិសេស។ តុលាការទាមទារយ៉ាងនេះ នាំឲ្យមានការផ្លាស់ប្តូរទម្លាប់ ដែលរដ្ឋាភិបាលកាណាដាតម្រូវនូវការធានា កុំឲ្យមានទោសប្រហារជីវិតពីសហរដ្ឋអាមេរិក ក្នុងតែករណីចាំបាច់ និងពិសេសតែប៉ុណ្ណោះ។ ការទាមទារដូចនេះ គឺដើម្បីឲ្យសមស្របតាមខ្លឹមសារ ដែលទាមទារក្នុងសន្ធិសញ្ញា បត្យាប័ន រវាងកាណាដា និងសហរដ្ឋអាមេរិក ជួយបញ្ចៀសកុំឲ្យមាន ការរំលោភសិទ្ធិមនុស្ស ដោយយោង ទៅនឹងសេចក្តីថ្លែងការជាសកល និងជាពិសេស កុំឲ្យមានការរំលោភច្បាប់ របស់កាណាដា ដែលលុបចោលទោសប្រហារជីវិត។[59]

យើងឃើញថា ចំពោះករណីពិសេសនេះវិញ សហរដ្ឋអាមេរិក អាចធ្វើការប្រហារជីវិតរាល់អ្នកទោសដែលបានរងនូវបទចោទបទមនុស្សឃាត និងរំលោភផ្លូវភេទលើកុមារ និងមនុស្សចាស់ អាចត្រូវអនុវត្ត នៅខែធ្នូ ២០១៩ និងខែមករា ឆ្នាំ២០២០ នេះបើតាមសេចក្តីថ្លែការ របស់ក្រសួងយុត្តិធម៌អាមេរិក។

---

[58] មាស បូរ៉ា, នីតិអន្តរជាតិសារធារណៈ(សកលវិទ្យាល័យឯកទេសកម្ពុជា, ២០១៣), ទំព័រ៧២-៧៥។

[59] មាស បូរ៉ា, នីតិអន្តរជាតិសារធារណៈ(សកលវិទ្យាល័យឯកទេសកម្ពុជា, ២០១៣), ទំព័រ៧៦-៧៧។

## ផ្នែកទី៤៖ ការធ្វើវិសោធនកម្មលើសន្ធិសញ្ញា

នៅក្នុងសន្ធិសញ្ញាអន្តរជាតិ ទោះបីជាកិច្ចព្រមព្រៀងដែលកើតឡើងដោយសុតចិត្តក៏ដោយ និងគោរព តាមគោលការណ៍ដោយស្ម័គ្រចិត្ត ប៉ុន្តែនៅពេលខ្លះដែលមានបញ្ហាកើតឡើង ដូច្នេះភាគីនៃសន្ធិសញ្ញា ក៏អាចធ្វើវិសោធនកម្មផងដែរ។

សន្ធិសញ្ញា អាចត្រូវបានធ្វើវិសោធនកម្ម ដោយសារមានការព្រមព្រៀងរវាងភាគីទាំងអស់ នៃសន្ធិសញ្ញា [60]។

ការធ្វើវិសោធនកម្ម ចំពោះសន្ធិសញ្ញាពហុភាគី សំណើរសុំធ្វើវិសោធនកម្មសន្ធិសញ្ញាពហុភាគី ដែលធ្វើឡើងរវាងភាគីទាំងអស់នៃសន្ធិសញ្ញាត្រូវធ្វើការជូនដំណឹងទៅ កាន់ភាគីចរចាទាំងអស់ ដែលភាគីនីមួយៗ នឹងមានសិទ្ធិ និងចូលរួមក្នុងការ[61]៖

-សម្រេចចិត្តអោយធ្វើនូវសកម្មភាពទាំងឡាយដែលទាក់ទងដល់សំណើសុំធ្វើវិសោធនកម្ម

-ធ្វើការចរចា និងចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងទាំងឡាយទៅលើធ្វើវិសោធនកម្មសន្ធិសញ្ញា

រដ្ឋដែលមានសិទ្ធិក្លាយទៅជាភាគីនៃសន្ធិសញ្ញា នឹងមានសិទ្ធិក្លាយជាភាគីនៃសន្ធិសញ្ញា ដែលបានធ្វើវិសោធនកម្មផងដែរ។

សេចក្តីព្រមព្រៀងលើការធ្វើវិសោធនកម្មមិនមានកម្លាំងចាប់បង្ខំរដ្ឋ ដែលជាភាគីនៃសន្ធិសញ្ញា តែមិនមែនជាភាគីនៃកិច្ចព្រមព្រៀងធ្វើវិសោធនកម្ម។

រដ្ឋទាំងឡាយណា ដែលបានក្លាយជាភាគីនៃសន្ធិសញ្ញា ក្រោយពេលដែលកិច្ចព្រមព្រៀងធ្វើវិសោធនកម្មបានចូលជាធរមាន ប្រសិនបើមិនបានបង្ហាញឆន្ទៈផ្សេងពីនេះទេ នឹង៖

-ត្រូវចាត់ទុកថា ជាភាគីនៃសន្ធិសញ្ញាដែលបានធ្វើវិសោធកម្ម និង

-ត្រូវចាត់ទុកថា ជាភាគីនៃសន្ធិសញ្ញាដែលមិនបានធ្វើវិសោធនកម្ម នៅក្នុងទំនាក់ទំនងជាមួយភាគីដទៃដែលសន្ធិសញ្ញា ពុំមានកម្លាំងចាប់បង្ខំគោរពកិច្ចព្រមព្រៀងធ្វើវិសោធនកម្ម។

---

[60] សារព័ត៌មានFresh News

[61] មាត្រា៤០ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា(ទីក្រុងវីយែនថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩)

ភាគីពីរ ឬច្រើននៃសន្ធិសញ្ញាពហុភាគី អាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងធ្វើការកែប្រែសន្ធិសញ្ញា រវាងពួកគេបាន ប្រសិនបើ៖

១.ភាពអាចប្រព្រឹត្តទៅបាននៃការកែប្រែ ត្រូវបានចែងក្នុងសន្ធិសញ្ញា ឬក៏

- ការកែប្រែដែលបានលើកឡើង មិនត្រូវបានហាមឃាត់ដោយសន្ធិសញ្ញា និង៖
- មិនមានការប៉ះពាល់ដល់ភាគីដទៃទៀត ក្នុងការអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ច ដែលមានចែងក្នុងសន្ធិសញ្ញា
- មិនមានការទាក់ទងចំពោះបទបញ្ញត្តិណាដែលការធ្វើបដិបញ្ញត្តិនាំអោយផ្ទុយទៅនឹងការប្រតិបត្តិអោយមានប្រសិទ្ធិភាព ទៅតាមកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញាទាំងមូល។

២.លើកលែងតែមានករណី ដែលកើតមានចែងក្នុងកថាខណ្ឌ១ ចំណុចក ឬសន្ធិសញ្ញាមានចែងផ្ទុយ ពីនេះភាគីដែលបានលើកឡើងនូវសំណើសុំកែប្រែ ត្រូវធ្វើការជូនដំណឹងទៅភាគីដទៃទៀត ពីឆន្ទៈរបស់ ពួកគេក្នុងការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀង និងពីការកែប្រែទៅលើសន្ធិសញ្ញាដែលបានបញ្ញត្តិ។

## ផ្នែកទី៥៖ ការរួចផុតពីការទទួលខុសត្រូវពេលមិនអនុវត្តសន្ធិសញ្ញាអន្តរជាតិ

រដ្ឋមិនមែនសុទ្ធតែទទួលខុសត្រូវលើអំពើរបស់ខ្លួនទាំងអស់នោះទេ ពោលគឺនៅពេលខ្លះ រដ្ឋអាចគេចផុតពីការទទួលខុសត្រូវទាំងស្រុងតែម្តង ឬគេចផុតបានខ្លះៗ យោងទៅតាមករណីនីមួយៗ។

រដ្ឋអាចរួចផុតពីការទទួលខុសត្រូវក្នុងករណីមានដូចជា៖ កំហុសរបស់ជនគ្រោះ ការសមគំនិតរបស់ជនរងគ្រោះក្នុងការបង្កព្យសនកម្ម ការពារដោយធម្មានុរូប ឬប្រធានសក្តិ។ ជាឧទាហរណ៍ ការពារដោយ ធម្មានុរូបរបស់រដ្ឋចំពោះក្នុងរឿក្តីប្រាសាទព្រះវិហារ កម្ពុជា ទល់នឹងថៃ មានការប៉ះទង្គិចកងកម្លាំង ប្រដាប់អាវុធ រវាងប្រទេសទាំងពីរជាច្រើនដងពីជម្លោះប្រាសាទព្រះវិហារ ក្នុងពេលកំពុងប្រយុទ្ធនោះដែល កងកម្លាំងប្រដាប់អាវុធថៃ បានបាញ់ស្រោច មកលើប្រាសាទព្រះវិហារ និងមកកងទ័ព និងប្រជាជនកម្ពុជា ភាគីកម្ពុជាទាំងតែ អត់ធ្មត់ និងព្យាយាមដោះស្រាយជម្លោះដោយសន្តិវិធី ក្នុងនាមនជាប្រទេសភូមិផងរបងជាមួយ និងចង់ឱ្យក្លាយជាតំបន់អភិវឌ្ឍន៍នៅតាមខ្សែបន្ទាត់ព្រំដែន ជាពិសេស គឺចង់មានទេសចរណ៍ ចេញចូលមកទស្សនា ប្រាសាទព្រះវិហារ របស់កម្ពុជាដែលតាមអំណាចសាលដីការបស់ តុលាការក្រុងឡាអេ ដោយផ្អែកលើសំអាងហេតុតុលាការ៖ ដោយមាន

សំឡេង៩ ទល់នឹង៣ សម្រេចថា ប្រាសាទព្រះវិហារ ស្ថិតនៅក្នុងទឹកដីក្រោម អធិបតេយ្យ របស់ប្រទេសកម្ពុជា ដោយសំឡេង៩ទល់នឹង៣ ប្រទេសថៃមានកាតព្វ កិច្ចដកកងកម្លាំងទ័ព ឬប៉ូលីស ឬអ្នកថែរក្សា ឬឆ្មាំដទៃទៀត ដែលថៃបានដាក់ក្នុងប្រាសាទ ឬក្នុងតំបន់ក្បែរ ប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា ដោយសំឡេង ៧ទល់នឹង៥ សម្រេចថា ប្រទេសថៃមានកាតព្វកិច្ច ប្រគល់មកឱ្យប្រទេសកម្ពុជាវិញ នូវវត្ថុទាំងឡាយតាមប្រភេទ ដែលបាន បញ្ជាក់នៅក្នុង សេចក្ដីស្នើរសុំឱ្យ វិនិច្ឆ័យទី៥ របស់កម្ពុជា ដែលត្រូវបានយកចេញពីប្រាសាទ ដោយអាជ្ញាធរ របស់ថៃ ចាប់តាំងពីកាលបរិច្ឆេទ នៃការកាន់កាប់ប្រាសាទនេះដោយប្រទេសថៃ នៅឆ្នាំ១៩៥៤[62] ។ ប៉ុន្តែនៅ ឆ្នាំ២០០៨ មានការផ្ទុះអាវុធ ជាមួយគ្នារវាង ប្រទេសទាំងពីរ នៅតាមបណ្ដោយ ប្រាសាទតាមាន់ ប្រាសាទតាក្របី និងតំបន់ជិតប្រាសាទព្រះវិហារ ដែលបង្ករឡើងដោយប្រទេសថៃ ដែលធ្វើអោយខូចដល់ប្រាសាទទាំងបី និងវត្តកែវ សិក្ខាគិរីស្វារៈ ដែលថៃប្រើកាំ ភ្លើងក្លែងប្រភេទ ១៣៥mm ១៥៥mm គ្រាប់បែកចង្កោម ដោយទប់នឹងការឈ្លានពាន មកលើបូរណភាពដែនដី ក៏ដូចជា ប្រាសាទ បេតិកភ័ណ្ឌរបស់មុនស្សជាតិ និងពិភពលោក កងទ័ពកម្ពុជាបាន ប្រើនូវ សិទ្ធិការពារខ្លួន និងស្វ័យការពារ នៅក្នុងទឹកដី ដោយគោរពនូវជំហររបស់ រាជរដ្ឋាភិបាលកម្ពុជា ថាទីមួយ សិទ្ធិការពារខ្លួននិងទីពីរគឺស្វ័យការពារនៅក្នុងទឹកដីរបស់ខ្លួន[63]។

[62] សាលដីកាទីក្រុងឡាអេ ១៥-មិថុនា-១៩៦២, (គំនិតផ្ដួចផ្ដើមបកប្រែជាភាសាខ្មែរដោយ សុខ អាន, បកប្រែដោយ ម៉ុង មុន្នីចរិយា និង យូរ ឧត្តរា)។

[63] Uon Chin, ការខូចខាតប្រាសាទព្រះវិហា (Radio Free Asia, ១៤-កុម្ភៈ-២០១១)។

# ជំពូកទី៤
# ការបិទបញ្ចប់សន្ធិសញ្ញាអន្តរជាតិ

នីតិវិធីនៃការរៀបចំ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ មានច្រើនដំណាក់កាល ហើយដំណាក់កាលនេះ គឺជាដំណាក់កាលចុងក្រោយ នៃការបិទបញ្ចប់សន្ធិសញ្ញាអន្តរជាតិ។ ការបិទបញ្ចប់នៃសន្ធិសញ្ញា អាចជាការផុតរលត់នៃសន្ធិសញ្ញា និងការបញ្ចប់សុពលភាពគតិយុត្តរបស់សន្ធិសញ្ញាអន្តរជាតិ។

ការបិទបញ្ចប់សន្ធិសញ្ញាអន្តរជាតិ គឺជាការបញ្ចប់ជាស្ថាពរនូវអានុភាពគតិយុត្តនៃសន្ធិសញ្ញា។ ការផុតរលត់នៃសន្ធិសញ្ញា មិនដូចគ្នានឹងការព្យួរទុកមួយរយៈនៃសន្ធិសញ្ញានោះទេ។ ការព្យួរទុកគ្រាន់តែជាការបញ្ចប់អានុភាពគតិយុត្តរបស់សន្ធិសញ្ញា សម្រាប់តែរយៈពេលណាមួយប៉ុណ្ណោះ[64]។

## ផ្នែកទី១៖ ការផុតរលត់នៃសន្ធិសញ្ញា

ការផុតរលត់នៃសន្ធិសញ្ញាអាចធ្វើឡើងតាមរបៀប២យ៉ាង គឺ ការបិទបញ្ចប់ដោយឆន្ទៈរបស់ភាគី ការបិទបញ្ចប់ដោយមូលហេតុផ្សេងៗ ។

### កថាខណ្ឌទី១៖ ការបិទបញ្ចប់ដោយឆន្ទៈរបស់ភាគី

ភាគី អាចព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញាតែម្តង ឬអាចព្រមព្រៀង តាមក្រោយមកទៀតបាន ដើម្បីបញ្ចប់អានុភាពគតិយុត្តរបស់សន្ធិសញ្ញាណាមួយ។

ការព្រមព្រៀងអាចជា[65]៖

- សន្ធិសញ្ញា ដែលធ្វើឡើងសម្រាប់រយៈពេលណាមួយកំណត់ទុកជាមុនច្បាស់លាស់ ហើយនៅពេលខណៈមកដល់សន្ធិសញ្ញា នេះផុតរលត់ដោយខ្លួនឯង។
- សន្ធិសញ្ញាដែលជាកិច្ចព្រមព្រៀងធ្វើឡើង ដើម្បីបំពេញកាតព្វកិច្ចណាមួយ ហើយនៅពេលកម្មវត្ថុនោះត្រូវបំពេញចប់សព្វគ្រប់ហើយ សន្ធិសញ្ញានេះ អាចបញ្ចប់ការបង្កើតអានុភាពគតិយុត្តរបស់ខ្លួនបាន។
- សន្ធិសញ្ញា ដែលកំណត់លក្ខខណ្ឌបញ្ចប់អានុភាពគតិយុត្តសន្ធិសញ្ញា ក្នុងករណីព្រឹត្តិការណ៍ណាមួយកើតឡើង ឬក៏ ក្នុងករណីព្រឹត្តិការណ៍ណាមួយមិនកើតឡើង។

[64] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៥៨។

[65] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៥៤។

- សន្ធិសញ្ញា ដែលរដ្ឋភាគីប្រកាសដកខ្លួន ស្របតាមមាត្រា៥៦ នៃអនុសញ្ញាវីយែន១៩៦៩។ ការប្រកាសដកខ្លួនអាចធ្វើជាឱឡារិក ឬអាចដោយតណ្ហីភាព។ សន្ធិសញ្ញា នឹងផុតរលត់នៅពេល ដែលការប្រកាសដកខ្លួនពីសំណាក់ជាភាគីមានច្រើនលើសលុប(មាត្រា៥៥ នៃអនុសញ្ញាវីយែន១៩៦៩) ជាទូទៅការសុំដកខ្លួនចេញពីសន្ធិសញ្ញាពហុភាគី អាចធ្វើទៅបានដោយភាគី វាគ្មានប៉ះពាល់អ្វីឡើយដល់ជោគវាសនានៃសន្ធិសញ្ញាបែបនេះ ប្រសិនបើការសុំដកខ្លួនពីសំណាក់រដ្ឋជាភាគី មិនមានចំនួនច្រើនលើសលុប ឬធ្វើដោយភាគី ដែលជាប់ទាក់ទងនឹងកម្មវត្ថុនៃសន្ធិសញ្ញានោះទេ។

### កថាខណ្ឌទី២៖ ការបិទបញ្ចប់ដោយមូលហេតុផ្សេងៗ

ការបិទបញ្ចប់ដោយមូលហេតុផ្សេងៗ អាចជាការបិទបញ្ចប់សន្ធិសញ្ញាដោយហេតុការណ៍ខាងក្រៅ។

សន្ធិសញ្ញាត្រូវផុតរលត់លែងមានសុពលភាពគតិយុត្តរបស់វាដោយសារវាទទួលរងនូវការកកើតហេតុការណ៍ពីក្រៅ ដែលមិនមែនជាឆន្ទៈរបស់ភាគី។ ការកកើតអាចមានដូចជាៈ

-ការកកើតឡើងនូវបទដ្ឋានអាជ្ញាបញ្ញាថ្មីមួយ អាចបង្កឱ្យសន្ធិសញ្ញាមួយ ដែលមានពីមុនមកអាចផុតរលត់បាន ប្រសិនបើសន្ធិសញ្ញានេះផ្ទុយនឹងបទដ្ឋានអាជ្ញាបញ្ញាថ្មីនេះ។[66]

-មានការប្រែប្រួលខាងកម្មវត្ថុនៃសន្ធិសញ្ញា ឬការផ្លាស់លក្ខន្តិកៈ នៃរដ្ឋភាគីសន្ធិសញ្ញា។ ឧទា. សន្ធិសញ្ញាដែលចែងអំពីកោះមួយ ហើយកោះនោះលិចបាត់លែងមានតទៅទៀត សន្ធិសញ្ញា ដែលមានរដ្ឋភាគីណាមួយប្រែប្រួលបុគ្គលភាពគតិយុត្តរបស់វា ដូចជា ពីមុនមាន អាល្លឺម៉ង់ខាងលិច និង អាល្លឺម៉ង់ខាងកើត ឥឡូវ លែងមានតទៅទៀត ហើយមានអាល្លឺម៉ង់តែមួយជំនួសវិញ។[67]

- អនុសញ្ញាទីក្រុងវីយែនបានសំដែងថា ការប្រកាសសុំរំលាយសន្ធិសញ្ញាមួយជាឯកតោភាគី របស់ រដ្ឋជាភាគីណាមួយ គឺជាទង្វើខុសច្បាប់អន្តរជាតិ ហើយពុំអាចធ្វើឱ្យសន្ធិសញ្ញាផុតរលត់បានឡើយ។ ក៏ប៉ុន្តែមានអញ្ញត្រកម្មពីរ ចំពោះការប្រកាសសុំរំលាយសន្ធិសញ្ញាមួយជាឯកតោភាគីនេះ គឺទី១ សន្ធិសញ្ញានឹងត្រូវផុតរលត់ទៅបានប្រសិនបើមានរដ្ឋភាគីណាមួយរំលោភបំពានលើបញ្ញត្តិជាសារវន្តរបស់សន្ធិសញ្ញានេះ។

ក៏ប៉ុន្តែអញ្ញត្រកម្មនេះពុំអាចអនុវត្តចំពោះសន្ធិសញ្ញាស្តីពីមនុស្សធម៌ឡើយ។ អញ្ញត្រកម្មទី២ ភាគីអាច លើកយកកា

---

[66] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦៤។

[67] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៦២។

រផ្លាស់ប្តូរជាមូលដ្ឋាននៃកាលៈទេសៈរបស់រដ្ឋខ្លួន ដើម្បីសុំរលាយសន្ធិសញ្ញា ដោយគោរពលក្ខខ័ណ្ឌមួយគឺ កាលៈទេសៈ ដែលលើកឡើងគឺ ត្រូវតែជាមូលដ្ឋានជាសារវ័ន្តនៃការយល់ព្រមរបស់ភាគី ប្រសិនបើវាមានការផ្លាស់ប្តូរទាល់ តែវាធ្វើឱ្យកាតព្វកិច្ចដែលត្រូវគោរពបន្តទៅទៀតប្តូររូបរាងទាំងស្រុងតែម្តង ។[68]

អនុសញ្ញាវីយែនបានបញ្ជាក់បន្ថែមថា កាសុំរំលាយសន្ធិសញ្ញា ដែលធ្វើឡើង តាមការលើកយកកា រផ្លាស់ប្តូរកាលៈទេសៈ មកអះអាង ពុំអាចធ្វើទៅបានឡើយ ចំពោះសន្ធិសញ្ញាព្រំដែន។ យុត្តាធិការអន្តរជាតិ ធ្វើការពិនិត្យយ៉ាងតឹងរឹងជាទីបំផុត ចំពោះអំណះអំណាងតាមការផ្លាស់ប្តូរកាលៈទេសៈ ជាក់ស្តែងមកដល់បច្ចុប្បន្ននេះ ពុំទាន់មានការយល់ ព្រមណាមួយទៅលើអំណះអំណាង ដែលលើកឡើងអំពីការផ្លាស់ប្តូរកាលៈទេសៈនោះទេ។ ការផ្លាស់ប្តូរកាលៈទេសៈ អាចជាករណីមានការ ផ្លាស់របបនយោបាយក្នុងរដ្ឋ ដូចជាពីរបបសេរីនិយមទៅជា របបសង្គមនិយមជាដើម។ល។[69]

ការប្រកាសសុំរំលាយសន្ធិសញ្ញាមួយជាឯកតោភាគី របស់រដ្ឋជាភាគីណាមួយ គឺជាទង្វើខុសច្បាប់អន្តរជាតិ ហើយ ពុំអាចធ្វើឱ្យសន្ធិសញ្ញាផុតរលត់បានឡើយ។ ក៏ប៉ុន្តែមានអញ្ញត្រកម្មពីរចំពោះ ការប្រកាសសុំរំលាយសន្ធិសញ្ញាផុតរលត់បានឡើយ[70]។ ក៏ប៉ុន្តែមាន អញ្ញត្រកម្មពីរចំពោះ ការប្រកាសសុំរំលាយសន្ធិសញ្ញា ណាមួយជាឯកតោភាគី នេះ គឺទី១ សន្ធិសញ្ញា នឹងត្រូវផុតរលត់ទៅបាន ប្រសិនបើមានរដ្ឋភាគីណាមួយ រំលោភបំពានលើបញ្ញត្តិជាសារវ័ន្តរបស់សន្ធិសញ្ញានេះ[71]។ ក៏ប៉ុន្តែ អញ្ញត្រកម្មនេះពុំអាចអនុវត្តចំពោះ សន្ធិសញ្ញាស្តីពីមនុស្សធម៌ឡើយ។ អញ្ញត្រកម្មទី២ ភាគីអាចលើកយកការផ្លាស់ប្តូរជាមូលដ្ឋាននៃកាលៈទេសៈរបស់រដ្ឋខ្លួន ដើម្បីសុំរំលាយសន្ធិសញ្ញា ដោយគោរពលក្ខខ័ណ្ឌ មួយគឺ កាលៈទេសៈ ដែលលើកឡើងគឺ ត្រូវតែជាមូលដ្ឋានជាសារវ័ន្តនៃការយល់ព្រមរបស់ភាគី ប្រសិនបើវាមានការផ្លាស់ប្តូរទាល់តែវាធ្វើឱ្យកាតព្វកិច្ចដែលត្រូវគោរពបន្តទៅទៀតប្តូររូបរាងទាំងស្រុងតែម្តង[72]។

---

[68] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦៦។

[69] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៦៣។

[70] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៥៦។

[71] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦០។

[72] Vienna Convention 1969 (សន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩), មាត្រា៦០។

## ផ្នែកទី២៖ការបញ្ចប់សុពលភាពគតិយុត្តរបស់សន្ធិសញ្ញាអន្តរជាតិ

ការបញ្ចប់សុពលភាពគតិយុត្តផ្នែកខ្លះនៃសន្ធិសញ្ញា អាចធ្វើទៅបាននៅផ្នែកណាមួយ នៃមាត្រាណាមួយ នៃខ្លឹមសារសន្ធិសញ្ញា នៅពេលមានសេចក្តីថ្លែងការ ឬពិធីសារមួយសម្រាប់បំពេញបន្ថែមទៅលើសន្ធិសញ្ញា ឬបញ្ចប់សុពលភាពទាំងស្រុង ដែលសន្ធិសញ្ញា ថ្មីណាមួយអាចធ្វើឡើង ដើម្បីជំនួសសន្ធិសញ្ញាមុនដោយសារការសម្របសម្រួលទៅតាមស្ថានភាពថ្មី នៃសង្គមមនុស្សជាតិ។ ជាទូទៅនៅក្នុងអវសានកិច្ចរបស់វា សន្ធិសញ្ញា បានព្រាងទុកនូវល័ក្ខខ័ណ្ឌនៃការធ្វើវិសោធកម្ម ហើយវិសោធនកម្មនេះអាចសម្រេចឡើង ដោយការបោះឆ្នោតយក សំលេងភាគច្រើន ។[73]

[73] អ៊ឹង វឌ្ឍា, នីតិអន្តរជាតិសារធារណៈ (រាជធានីភ្នំពេញ, ២០១៨), ទំព័រ៦៦។

# សេចក្តីសន្និដ្ឋាន

ជារួមយើងអាចមើលឃើញថា នីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ ជានីតិវិធី សម្រាប់ឱ្យរដ្ឋ យកទៅអនុវត្តនៅពេលមានការចុះសន្ធិសញ្ញារវាងរដ្ឋ និងរដ្ឋរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ សម្រាប់ភ្ជាប់ទំនាក់ទំនងគតិយុត្តដែលជាចំណងរបស់រដ្ឋជាសមាជិក ឬអង្គការអន្តរជាតិ នៃសន្ធិសញ្ញាអន្តរជាតិ ពេលដែលសន្ធិសញ្ញា ចូលជាធរមាន និងត្រូវដាក់ឱ្យគ្រប់រដ្ឋ និងអង្គការជាសមាជិកអនុវត្ត ដោយគោរពនូវខ្លឹមសារនៃសន្ធិសញ្ញា។

មុននឹងមានកិច្ចចុះសន្ធិសញ្ញាអន្តរជាតិ រដ្ឋមានកាព្វកិច្ចរៀបចំនីតិវិធីនីមួយៗ ទៅតាមលំដាប់ លំដោយនៃការរៀបចំ និងការអនុវត្តនូវសន្ធិសញ្ញា។ ដំណាក់កាលដំបូង រដ្ឋត្រូវចរចាជាមុននូវខ្លឹមសារនៃ សន្ធិសញ្ញា ចំពោះរដ្ឋរបស់ខ្លួន ក្រែងថាចំណុចណាមួយរដ្ឋរបស់ខ្លួនមិនអាចអនុវត្តបាន ក៏អាចដាក់ជាខសន្យាពិសេស ចំពោះមាត្រាណាមួយ ឬផ្នែកណាមួយនៃខ្លឹមសារសន្ធិញ្ញា ដែលមិនអាចអនុវត្តបាន បន្ទាប់ពីបានចរចាហើយ រដ្ឋត្រូវតែចុះហត្ថលេខាលើ សន្ធិសញ្ញាដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីក្រសួង ការបរទេស ឬអ្នកដែលទទួលបាននូវសិទ្ធិប្រទានដោយប្រមុខរដ្ឋ ឬនាយករដ្ឋមន្ត្រី ក្នុងការតំណាង ដល់ប្រទេសឬរដ្ឋរបស់ខ្លួន ក្នុងការចុះហត្ថលេខាមុននឹង ការផ្តល់សច្ចាប័នដោយរដ្ឋសភា។

សន្ធិសញ្ញា គឺជាលិខិតតូបករណ៍មួយ ដែលជាការចុះកិច្ចព្រមព្រៀងរវាងពីរប្រទេស ឬច្រើន ឬដោយអង្គការអន្តរជាតិ ទៅតាមរបៀបផ្សេងៗពីគ្នា នៃសន្ធិសញ្ញានីមួយៗ។ សន្ធិសញ្ញាមានសារៈ សំខាន់ក្នុងកិច្ចសហប្រតិបត្តិការលើ គ្រប់វិស័យនៃរដ្ឋនីមួយៗដែលជាសមាជិក ព្រមទាំងអង្គការអន្តរជាតិ សម្រាប់ទំនាក់ទំនងនយោបាយ ការទូត សេដ្ឋកិច្ច ។

ភាគីហត្ថលេខី មានតួនាទីសំខាន់ក្នុងការអនុវត្តឱ្យបាននូវខ្លឹមសារសន្ធិសញ្ញា និងផ្សព្វផ្សាយ តាមប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមរបស់ខ្លួន លើគ្រប់ប្រព័ន្ធ ដើម្បីឱ្យសមាជិកនៃសសង្គមអន្តរជាតិ ព្រមទាំងប្រជាពលរដ្ឋ ទូទៅចូលរួមគោរព និងអនុវត្តនូវបទបញ្ញត្តិដែលទាក់ទង នឹងខ្លឹមសារនៃមាត្រាណាមួយ ឬផ្នែកណាមួយនៃសន្ធិសញ្ញា ជាពិសេសរដ្ឋត្រូវតែមានទំនួលខុសត្រូវខ្ពស់ចំពោះការអនុវត្ត សន្ធិសញ្ញាដែលខ្លួនបានចុះ និងព្រមទទួលយក ព្រមទាំងគោរពនូវ ស្ទិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ពីសំណាក់ប្រជាពលរដ្ឋ នៅពេលដែលខ្លួនមានកំហុស ទាក់ទិននឹង ការមិនអនុវត្តនូវខ្លឹមសារ ឬប្រព្រឹត្ត ប្រាស់ចាកនូវពីគោលបំណងនៃសន្ធិសញ្ញា។

# អនុសាសន៍

ក្រោយពីការសិក្សាស្រាវជ្រាវ និងចងក្រងនូវ "**នីតិវិធីនៃការរៀបចំធ្វើ និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ**" រួចមក បានសង្កេតឃើញថា បានទទួលការអប់រំច្រើនពាក់ព័ន្ធនឹងនីតិសន្ធិសញ្ញាអន្តរជាតិ និងចំណេះដឹងពាក់ព័ន្ធនឹងការនីតិវិធីនីមួយ នៃការរៀបចំធ្វើសន្ធិសញ្ញា ព្រមទាំងការអនុវត្តសន្ធិសញ្ញា។ ហេតុនេះក្នុងកិច្ចការស្រាវជ្រាវ មួយនេះ បានបំផុសជាគំនិតផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

១-គ្រប់ភាគីហត្ថលេខី មានកាតព្វកិច្ចត្រូវគោរពរាល់នីតិវិធី នៃការចុះសន្ធិសញ្ញា ទាំងមុនពេល អំឡុងពេល និងក្រោយពេល នៃការចុះសន្ធិសញ្ញា ដើម្បីធានាប្រក្រតីភាព។ ផងដែរ ភាគីហត្ថលេខីត្រូវ ដើម្បីបញ្ចៀសអោយបានរាល់វិវាទ និងធ្វើយ៉ាងណាបង្កើតអោយបានជាប្រយោជន៍សន្តិសហវិជ្ជមាន។ តែបើជៀសមិនរួច ហើយជួបប្រទះនឹងវិវាទ ភាគីហត្ថលេខី ត្រូវធ្វើការដោះស្រាយជម្លោះដោយស្របទៅតាម នីតិវិធីនៃនីតិអន្តរជាតិជាធរមាន ហើយត្រូវគោរពអោយបានម៉ឺងម៉ាត់បានរាល់ សេចក្តីសម្រេចនោះ ទើបផ្ទៃរាបមួយនេះមានសណ្តាប់ធ្នាប់របៀបរៀបរយ និងប្រព្រឹត្តទៅបានរលូន។

២-រាល់ប្រធាននៃនីតិអន្តរជាតិ គួរមានឥរិយាបទ ឯកភាព សាមគ្គីភាព និងមានចក្ខុវិស័យរួម ដើម្បីជាឆ្លុងមួយ ក្នុងការកសាងនីតិអន្តរជាតិសារធាណៈប្រកបដោយវឌ្ឍនភាព ចីរភាព សណ្តាប់ធ្នាប់ របៀបរៀបរយល្អ តាមការចង់បានរបស់ មនុស្សជាតិ ដោយជាពិសេសត្រូវគិតទៅដល់ចំណុចអាទិភាពរួមមួយ ដែលជាឧត្តមប្រយោជន៍សមូហភាព នៅក្នុងសហគមន៍អន្តរជាតិមួយទាំងមូល ជាជាងប្រយោជន៍សួនតួរ ដែលនាំអោយមានការបង្អាក់ដំណើរក្នុងការរៀបចំសណ្តាប់ធ្នាប់ល្អក្នុង ផ្ទៃរាបអន្តរជាតិ។

# ឯកសារយោង


## ប្រភពលិខិតបទដ្ឋានគតិយុត្តជាតិ

១.រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

២.ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ០៥ តុលា ២០០៧។

៣.ក្រឹត្យច្បាប់លេខ ៣៨, ២៨ តុលា ១៩៨៨។

## ប្រភពលិខិតតូបករណ៍អន្តរជាតិ

១.អនុសញ្ញាទីក្រុងវីយែន ស្តីពីនីតិសន្ធិសញ្ញា(Vienna Convention on the Law of Treaties - VLTC) ឆ្នាំ១៩៦៩។

២.អនុសញ្ញាទីក្រុងវីយែន ស្តីពីការបន្តនៃរដ្ឋក្នុងការគោរពសន្ធិសញ្ញា (Vienna Convention on the Succession of States in respected of Treaties) ឆ្នាំ១៩៧៨។

៣.អនុសញ្ញាទីក្រុងវីយែន ស្តីពីនីតិនៃសន្ធិសញ្ញា រវាងអង្គការអន្តរជាតិ ឬរវាងរដ្ឋនិងអង្គការអន្តរជាតិ(Vienna Convention on the Law of treaties between International organization or between States and International organization) ឆ្នាំ១៩៨៦។

## ប្រភពពីសៀវភៅសិក្សា និងឯកសារស្រាវជ្រាវផ្សេងៗ

១.លោក អ៊ឹង រដ្ឋា. ២០១៨. នីតិអន្តរជាតិសាធារណៈ. ភ្នំពេញ។

២.លោក មាស ប៉ូវ៉ា. ២០១៣. នីតិអន្តរជាតិសាធារណៈ. ភ្នំពេញ៖ សាកលវិទ្យាល័យឯកទេសនៃ  កម្ពុជា។

៣.លោក ខៀវ ថវិកា. ២០០១. ទំនាក់ទំនងអន្តរជាតិ. ភ្នំពេញ។

៤.Vienna Convention on the Law of Treaties អនុសញ្ញាទីក្រុងវៀន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា, បកប្រែក្រៅផ្លូវការ លោក អ៊ុំ ប៉ូលី។

## ប្រភពពីគេហទំព័រ

១.រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា. http://en.nac.org.kh/

២.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ. https://www.mfaic.gov.kh/

៣.អង្គការសហប្រជាជាតិ. https://treaties.un.org/

៤.សារព័ត៌មាន Fresh News. http://freshnewsasia.com/index.php/en/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

# ឧបសម្ព័ន្ធ២

# ឧបសម្ព័ន្ធ៣